# ជំពូកទី ៥

Draft

# ជំពូកទី៥: ការចូលរួមជាសាធារណៈ

## ៥.១ សេចក្តីផ្តើម

ការចូលរួមជាសាធារណៈ គឺមានន័យយ៉ាងទូលំទូលាយ ផ្តល់ឱកាស ឬអនុញ្ញាតឱ្យសហគមន៍ និងប្រជាជន ឬគ្រួសារដែលរងផលប៉ះពាល់ដើម្បីចូលរួមក្នុងកិច្ចប្រជុំក្នុងការទទួលព័ត៌មានគំរោង និងសំណើសុំ/ផ្តល់មតិយោបល់នៅលើសកម្មភាពគំរោង។ ការចូលរួមជាសាធារណៈ គឺរួមទាំងការប្រជុំពិគ្រោះយោបល់ជាមួយអ្នកដែលពាក់ព័ន្ធ ឬក៏ស្ថាប័នសំខាន់ៗដែលមានការពាក់ព័ន្ធទៅនឹងសកម្មភាពគំរោង។ កិច្ចប្រជុំនេះ គឺជាផ្នែកមួយមានសារសំខាន់ណាស់ជួយធ្វើអន្តរាគមន៍នៅក្នុងការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដើម្បីអនុវត្តគំរោងឱ្យរលូន។ ប្រសិនបើ ការសិក្សាមានការធ្វេសប្រហែស ជាហេតុបណ្តាលឱ្យផលប៉ះពាល់អវិជ្ជមានមិនអាចគ្រប់គ្រងបានទៅលើធនធានបរិស្ថាន និងសង្គមជុំវិញតំបន់អនុវត្តន៍គំរោង។

ទោះជាយ៉ាងណាក៏ដោយ យោងទៅលើគោលការណ៍ណែនាំនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន របស់ក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា តំរូវឱ្យអនុវត្តនូវកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ និងផ្តល់ឱកាសឱ្យមានការចូលរួមជាសាធារណៈ សំរាប់ដំណើរការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន។ ក្រុមគោលដៅរបស់គំរោងនឹងត្រូវបានអញ្ជើញឱ្យចូលរួមដូចជា ប្រជាជនរងផលប៉ះពាល់ អាជ្ញាធរមូលដ្ឋាន សមាជិកសហគមន៍ មនុស្សសំខាន់ៗ និងអ្នកដែលពាក់ព័ន្ធផ្សេងៗទៀតដើម្បីចូលរួម និងស្វែងរកទស្សនៈរបស់ពួកគេទៅលើការអភិវឌ្ឍគំរោង។

Draft

## ៥.២ គោលបំណង

គោលបំណងនៅក្នុងការប្រជុំពិគ្រោះយោបល់ជាសាធារណៈ និង កិច្ចប្រជុំជាមួយអ្នកដែលពាក់ព័ន្ធសំរាប់ការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោង**មរកត** គឺដើម្បីផ្សព្វផ្សាយព័ត៌មានគំរោង ប្រមូលយោបល់ផ្សេងៗ ឬ ក៏ចូលរួមជាគំនិតពីអ្នកដែលពាក់ព័ន្ធទាំងឡាយ ដើម្បីកែលំអផែនការរបស់គំរោង ការសាងសង់គំរោង និងការអនុវត្តគំរោងប្រព្រឹត្តិទៅដោយរលូន។ ជាងនេះទៅទៀត កិច្ចប្រជុំ និងការពិគ្រោះយោបល់នេះអាចទទួលបាននូវព័ត៌មាន និងបញ្ហាបន្ថែមទៀតដែលជាប់ពាក់ព័ន្ធទៅនឹងស្ថានភាពសង្គម និងសេដ្ឋកិច្ចនៅក្នុងតំបន់គំរោង ដែលផ្តល់ឱ្យទិន្នន័យមូលដ្ឋានគ្រប់គ្រាន់ទៅដល់ក្រុមអ្នកសិក្សាអភិវឌ្ឍន៍គំរោង ក្នុងបំណងឱ្យបានសមស្របតាមបច្ចេកទេស សេដ្ឋកិច្ច និងបរិស្ថាន។

ការចូលរួមកិច្ចប្រជុំនេះ ប្រព្រឹត្តទៅតាមរយៈកិច្ចសម្ភាសន៍ជាមួយឯកត្តបុគ្គលនៃក្រុមគោលដៅ (តាមគ្រួសារនីមួយៗ និងស្ថាប័នដែលពាក់ព័ន្ធ) ទាំងអស់នៅក្នុងអំឡុងពេលសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង។ នៅក្នុងផ្នែកនេះដែរ បានជួបជាមួយអ្នកដែលរងផលប៉ះពាល់ផ្ទាល់ និងអ្នកដែលរងផលប៉ះពាល់ដោយប្រយោល ព្រមទាំងស្ថាប័នដែលពាក់ព័ន្ធទាំងឡាយ ដើម្បីផ្តល់ឱកាសឱ្យពួកគេបញ្ចេញយោបល់ទៅលើគំរោងតាមរយៈការប្រជុំនេះ។

## ៥.៣ វិធីសាស្ត្រ

វិធីសាស្ត្រជាទូទៅត្រូវបានប្រើប្រាស់នៅក្នុងការពិគ្រោះយោបល់ជាសាធារណៈ និងការប្រជុំជាមួយអ្នកដែលពាក់ព័ន្ធនោះគឺ:

- រៀបចំសុំលិខិតអនុញ្ញាតសំរាប់ការសិក្សាតាមតំបន់គំរោងពីក្រសួងបរិស្ថាន និងខេត្តព្រះសីហនុ ។
- ធ្វើការជ្រើសរើសអ្នកដែលពាក់ព័ន្ធសំខាន់ៗ និងប្រជាជនដែលរងផលប៉ះពាល់ ។
- ធ្វើការណាត់ជួបជាមួយមនុស្សសំខាន់ៗនៃស្ថាប័នដែលពាក់ព័ន្ធទាំងឡាយ ។
- រៀបចំការប្រជុំជាមួយនឹងប្រជាជនដែលនឹងរងផលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋាននៅក្នុងសហគមន៍ជាពិសេសសំរាប់ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១ ។
- រៀបចំការប្រជុំជាមួយមន្ទីរដែលពាក់ព័ន្ធ និងអង្គភាពនានា នៅក្នុងកំរិតថ្នាក់ខេត្ត សំរាប់ធ្វើកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ ។
- ធ្វើលិខិតអញ្ជើញ និងរៀបចំសម្ភារះ/អត្ថបទសំរាប់ធ្វើបទបង្ហាញ ។
- ចែកខិតប័ណ្ណ និងផ្សព្វផ្សាយព័ត៌មានតាមវិទ្យុដល់សហគមន៍ និងខេត្តមុនពេលកិច្ចប្រជុំចាប់ផ្តើម ។
- រៀបចំថតរូប និងអ្នកកត់ត្រារាល់សកម្មភាពទាំងអស់នៅក្នុងកិច្ចប្រជុំ ។
- ធ្វើកំណត់ហេតុពីលទ្ធផលដែលទទួលបានពីកិច្ចប្រជុំ និងការពិគ្រោះយោបល់ទាំងអស់ ដើម្បីចងក្រងដាក់ចូលក្នុងរបាយការណ៍សិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA).

## ៥.៤ ការពិគ្រោះយោបល់ជាសាធារណៈ

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈត្រូវបានធ្វើឡើង២លើកក្នុងអំឡុងពេលសិក្សាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១ គឺដើម្បីផ្តល់ព័ត៌មានគំរោងទៅដល់សហគមន៍មូលដ្ឋាន និងពិនិត្យមើលបញ្ហាបរិស្ថានដែលនឹងអាចកើតមានឡើងពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គំរោង ។ ការរៀបចំកិច្ចប្រជុំត្រូវបានធ្វើឡើងតាមរយៈអ្នកដឹកនាំក្នុងកំរិតថ្នាក់ឃុំ និងភូមិ ។

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ ត្រូវបានរៀបចំបន្ទាប់ពីការបញ្ចប់ការងារចុះសិក្សានៅទីវាលក្នុងតំបន់គំរោង និងប្រមូលបាននូវលទ្ធផលសិក្សាដ៏ត្រឹមត្រូវគ្រប់គ្រាន់ រួមទាំង ការរចនាប្លង់វិស្វកម្ម ការសិក្សាការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់គំរោង និងការសិក្សាផ្សេងៗទៀត ដើម្បីបង្ហាញទៅដល់អ្នកដែលពាក់ព័ន្ធ។ តំណាងមកពីសហគមន៍ដែលរងផលប៉ះពាល់ គ្រប់មន្ទីរពាក់ព័ន្ធនៅក្នុងខេត្ត ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀតមកពីភ្នំពេញដែលពាក់ព័ន្ធទៅនឹងគំរោងក៏ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនោះផងដែរ ។

សកម្មភាពពិស្តារ និងលទ្ធផលនៃកិច្ចប្រជុំពិគ្រោះយោបល់នីមួយៗត្រូវបានពិព័ណ៌នានៅក្នុងចំណងជើងរង និង កថាខ័ណ្ឌដូចខាងក្រោម ។

### ៥.៤.១. ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១

មានភូមិចំនួន៣ក្នុងនោះមានភូមិ១ ភូមិ២ និងភូមិ៣ ស្ថិតនៅក្នុងសង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ត្រូវបានជ្រើសរើសសំរាប់ចូលរួមការប្រជុំពិគ្រោះយោបល់លើកទី១ ដែលធ្វើឡើងដាច់ដោយឡែកពីគ្នា។ នៅក្នុងកិច្ចប្រជុំលើកទី១នេះ ត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ២១ ២២ និង ២៥ ខែកក្កដា ឆ្នាំ២០០៩។ ព័ត៌មានពិស្តារសំរាប់កិច្ចប្រជុំ នឹងបង្ហាញជូននៅក្នុងតារាងទី ៥.៣.១-១។

តារាង ៥.៣.១-១: សកម្មភាពពិស្តារសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១

| ល.រ | សកម្មភាព | កំណត់សំគាល់ |
|---|---|---|
| ១ | **មុនពេលប្រជុំ** | |
| ១.១ | ការបញ្ជូនបុគ្គលិក និងរៀបចំអ្នកភូមិ ឬអ្នកដែលចូលរួម រៀបចំទីកន្លែង នៅក្នុងភូមិនៃសង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ | រយៈពេលរៀបចំ២ថ្ងៃ មុនកិច្ចប្រជុំ |
| ២ | **ក្នុងអំឡុងពេលប្រជុំ** | |
| ២.១ | ចុះឈ្មោះអ្នកចូលរួមប្រជុំដោយមានផ្តិតមេដៃ ឬចុះហត្ថលេខា | ៨:០០- ៨:៣០ ព្រឹក |
| ២.២ | តំណាងក្រុមសិក្សាបានណែនាំខ្លួនឱ្យស្គាល់ និងបង្ហាញពីគោលបំណងនៃអង្គប្រជុំ និងមានថតរូបទុកជាភស្តុតាង | |
| ២.៣ | ធ្វើការផ្សព្វផ្សាយព័ត៌មានគំរោងដល់អង្គប្រជុំដោយៈ ឧទ្ទេសនាម ចែកជូន ឯកសារ និងបង្ហាញជូននូវទីតាំងគំរោងតាមរយៈផែនទី និងសង្ខេបគំរោង⁽¹⁾ | ៨:៣០- ៩:៣០ ព្រឹក |
| ២.៤ | បំផុសគំនិត និងសួរសំណួរអំពីការយល់ដឹងពីគំរោងពីអ្នកចូលរួម ការបញ្ចេញគំនិតយោបល់ និង សំណួរផ្សេងៗ។ ក្នុងពេលនោះដែរ អង្គប្រជុំបានសំរាករយៈពេលខ្លីដើម្បីពិសានំ និងទឹកបរិសុទ្ធ។ | ៩:៣០- ១០:៤០ ព្រឹក |
| ២.៥ | ចំលើយតប និងដំណោះស្រាយរាល់សំនួរ សំណូមពរ និងមតិយោបល់របស់អ្នកចូលរួម នឹងត្រូវកត់ត្រា ដើម្បីដាក់ចូលទៅក្នុងរបាយការណ៍។ | |
| ២.៦ | បិទអង្គប្រជុំ:<br>- ចំណាប់អារម្មណ៍អង្គប្រជុំដោយប្រធានភូមិ/មេឃុំ<br>- ប្រមូលបញ្ជីឈ្មោះអ្នកចូលរួម និងជូនដំណឹងពីការធ្វើសំភាសន៍តាមគ្រួសារនីមួយៗ ដោយក្រុមសិក្សាសង្គមរបស់ KCC។ | |

**កំណត់សំគាល់:** [1] ព័ត៌មានគំរោងសង្ខេបជាភាសាខ្មែរ (ឧបសម្ព័ន្ធទី៧ក) និងផែនទីបង្ហាញទីតាំង និងប្លង់គំរោង។

ព័ត៌មានលំអិតនៃការប្រជុំពិគ្រោះយោបល់ជាមួយសាធារណៈលើកទី១ មានបង្ហាញជូននៅក្នុងតារាងទី ៥.៣.១-២ និងលទ្ធផលនៃកិច្ចប្រជុំត្រូវមានព័ណ៌នានៅក្នុងតារាងទី ៥.៣.១-៣ក និង ៥.៣.១-២ខ និង ៥.៣.១-៣គ ។

តារាង ៥.៣.១-២: ទីតាំង ពេលវេលា និងអ្នកចូលរួមប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១

| ថ្ងៃ ខែ ឆ្នាំ | ទីតាំងប្រជុំ | | | | | ចំនួនអ្នកចូលរួមប្រជុំ |
|---|---|---|---|---|---|---|
| | ភូមិ | សង្កាត់ | ក្រុង | ខេត្ត | ទីកន្លែងប្រជុំ | |
| ២១ កក្កដា ០៩ | ភូមិ១ | ៣ | ព្រះសីហនុ | ព្រះសីហនុ | កណ្តាលភូមិ១ | ៥៤នាក់/ស្រី៣២នាក់ |
| ២២ កក្កដា ០៩ | ភូមិ២ | ៣ | ព្រះសីហនុ | ព្រះសីហនុ | កណ្តាលភូមិ២ | ២៤នាក់/ស្រី១៤នាក់ |
| ២៥ កក្កដា ០៩ | ភូមិ៣ | ៣ | ព្រះសីហនុ | ព្រះសីហនុ | បឋមសិក្សាប៊ុរីកម្មករ | ៦១នាក់/ស្រី៤៥នាក់ |
| **សរុប** | | | | | | **១៣៩នាក់/ស្រី៩១នាក់** |

សំគាល់: សូមមើលបញ្ជីឈ្មោះអ្នកចូលរួមលំអិតនៅក្នុងឧបសម្ព័ន្ធទី ៧ខ ។

Draft

តារាង ៥.៣.១-៣ក: លទ្ធផលប្រជុំពិគ្រោះយោបល់ជាសាធារណៈនៅភូមិ១ (២១ ខែកក្កដា ឆ្នាំ២០០៩)

| ល.រ | ឈ្មោះអ្នកចូលរួម | មុខរបរ និងទីកន្លែង | គំនិតយោបល់ អនុសាសន៍ និងសំនួរ |
|---|---|---|---|
| ១ | អ្នកស្រី តាំង សុភាព | ប្រជាជន | - តើខ្ញុំអាចនេសាទនៅជុំវិញកោះពស់នេះបានទេ ប្រសិនបើគំរោងដំណើរការនោះ? |
| ២ | អ្នកស្រី សន ផុន | ប្រជាជន | - អ្នកស្រីបានសំណូមពរទៅដល់ក្រុមហ៊ុនដែលទាក់ទងទៅនឹងការវិនិយោគ នៅពេលដែលអ្នកភូមិរបស់យើងទៅនេសាទនៅជុំវិញតំបន់កោះពស់នេះសូមមេត្តាអនុញ្ញាតឱ្យពួកយើងខ្ញុំបានទៅនេសាទក្បែរតំបន់នោះផង ។ |
| ៣ | បងស្រី មុល ធឿន | ប្រជាជន | - បងស្រីបានសំណូមពរទៅដល់ម្ចាស់គំរោងឱ្យ ផ្តល់ការងារទៅដល់អ្នកភូមិមូលដ្ឋានផង នៅក្នុងអំឡុងពេលសាងសង់គំរោង ដោយធ្វើជាកម្មករ/បុគ្គលិកនៅក្នុងក្រុមហ៊ុន ។ |
| ៤ | បងស្រី ស្រី ម៉ាច | ប្រជាជន | - បងស្រីបានស្នើសុំឱ្យម្ចាស់គំរោងផ្តល់ការងារឱ្យប្រជាជនក្នុងស្រុកឱ្យបានច្រើន តាមដែលអាចធ្វើទៅបាននៅក្នុងអំឡុងពេលសាងសង់គំរោង ។ |

| | | | |
|---|---|---|---|
| ៥ | លោក សួន ចន្ទូ | ប្រជាជន | - លោកបានស្នើសុំឱ្យម្ចាស់គំរោងផ្តល់ទីតាំងសុវត្ថិភាពសំរាប់អ្នកនេសាទដើម្បីចូលចតនៅក្នុងចំណតនៅពេលពួកគេជួបប្រទះភ្លៀង ឬក៏ខ្យល់ខ្លាំង ។ |
| ៦ | អ្នកស្រី ឡាយ អួន | ប្រជាជន | - អ្នកស្រីបានស្នើសុំម្ចាស់គំរោងឱ្យអនុញ្ញាតដល់ប្រជាជនខ្មែរបានចូលទស្សនានៅក្នុងតំបន់កំសាន្តផងមិនឱ្យដូចជាឆ្នេរសុខា ពួកគេមិនអនុញ្ញាតឱ្យប្រជាជនចូលនោះទេ ។ |

សំណួរភាគច្រើនត្រូវបានឆ្លើយតបដោយក្រុមសិក្សាក្រោយពីសំណួរនីមួយៗបានបញ្ចប់ ។ ប្រជាជនបានយល់ច្បាស់អំពីស្ថានភាពរបស់គំរោង និងសកម្មភាពរបស់វា ។

ជាទូទៅអ្នកចូលរួមទាំងអស់នៅក្នុងភូមិ១ បានគាំទ្រគំរោង១០០%



Draft

រូបភាព ៥.៣.១-១: សកម្មភាពចូលរួមប្រជុំរបស់ប្រជាជននៅក្នុងភូមិ១

តារាង ៥.៣.១-៣ខ:លទ្ធផលប្រជុំពិគ្រោះយោបល់ជាសាធារណៈនៅភូមិ២ (២២ ខែកក្កដា ឆ្នាំ២០០៩)

| ឈ្មោះអ្នកចូលរួម | មុខរបរ និងទីកន្លែង | គំនិតយោបល់ អនុសាសន៍ និងសំណួរ |
|---|---|---|
| អ្នកស្រី ទេព ចន្ទី | ប្រជាជន | - តើពេលណាទៅទើបគំរោងនេះធ្វើការសាងសង់?<br>- អ្នកស្រីមានបំណងចង់ឱ្យគំរោងនេះដំណើរការបានរហ័ស |
| លោក ឡូត ឈួន | ប្រជាជន | - តើខ្ញុំអាចនេសាទត្រីនៅជុំវិញកោះពស់ ឬក៏ចតទូកនេសាទក្បែរឬជុំវិញតំបន់គំរោងនេះបានដែរឬទេ? |
| លោក យឹម ហៀង | មេភូមិ២ | - លោកសប្បាយចិត្តជាមួយនឹងគំរោងនេះណាស់ ពីព្រោះវាជាពេលវេលាមួយដ៏ល្អសំរាប់បង្កើតការងារ បង្កើនវិស័យទេសចរណ៍ និងកែលំអជីវភាពរបស់ប្រជាជន ជាពិសេសប្រជាជននៅក្នុងតំបន់ ។ |

សំណួរទាំងអស់ត្រូវបានឆ្លើយតបដោយក្រុមសិក្សា បន្ទាប់ពីសំណួរនីមួយៗ ។ ប្រជាជនបានយល់ច្បាស់អំពីស្ថានភាពរបស់គំរោង និងសកម្មភាពរបស់វា ។

អ្នកចូលរួមទាំងអស់នៅក្នុងអង្គប្រជុំបានគាំទ្រគំរោង១០០% និងចង់ឱ្យគំរោងមានដំណើរការឆាប់រហ័សទៀតផង ។




រូបភាព ៥.៣.១-២: សកម្មភាពចូលរួមប្រជុំរបស់ប្រជាជននៅក្នុងភូមិ២

តារាង ៥.៣.១-៣គ: លទ្ធផលប្រជុំពិគ្រោះយោបល់ជាសាធារណៈនៅភូមិ៣(២៥ ខែកក្កដា ឆ្នាំ២០០៩)

<table>
<tr><th>ឈ្មោះអ្នកចូលរួម</th><th>មុខរបរ និងទីកន្លែង</th><th>គំនិតយោបល់ អនុសាសន៍ និងសំណួរ</th></tr>
<tr><td>លោក ម៉ក ផន</td><td>ប្រជាជន</td><td>- មានអារម្មណ៍រីករាយជាមួយនឹងគំរោងអភិវឌ្ឍន៍ក្នុងប្រទេស<br>- គាត់ចង់ឱ្យគំរោងនេះដំណើរការបានឆាប់រហ័ស</td></tr>
<tr><td>អ្នកស្រី សុខ នី</td><td>ប្រជាជន</td><td>- ប្រជាជនភាគច្រើននៅក្នុងតំបន់នេះ គឺជាកម្មករសំណង់ ដូច្នេះចង់ឱ្យជ្រើសរើសកម្មករនៅក្នុងតំបន់នេះទៅ ជាពិសេសនៅក្នុងភូមិ៣។</td></tr>
<tr><td>លោក ភ័ក្រ សុភា</td><td>ប្រជាជន</td><td>- លោកមានការព្រួយបារម្ភអំពីបញ្ហាបរិស្ថាន មិនដឹងថាមានផលប៉ះពាល់បរិស្ថានយ៉ាងដូចម្តេចនោះទេ?</td></tr>
<tr><td colspan="3">សំណួរទាំងអស់ត្រូវបានឆ្លើយតបដោយក្រុមសិក្សា។ ប្រជាជនបានយល់ច្បាស់អំពីស្ថានភាពរបស់គំរោង និងសកម្មភាពរបស់វា។<br>អ្នកចូលរួមទាំងអស់នៅក្នុងអង្គប្រជុំបានគាំទ្រគំរោង១០០% និងចង់ឱ្យគំរោងមានដំណើរការឆាប់រហ័ស។</td></tr>
</table>

Draft




រូបភាព ៥.៣.១-៣: សកម្មភាពចូលរួមប្រជុំរបស់ប្រជាជននៅក្នុងភូមិ៣

ផ្អែកទៅលើការសិក្សាស្រាវជ្រាវបានរកឃើញថា អ្នកចូលរួមទាំង៣ភូមិបានយល់ព្រមជាមួយនឹងការអភិវឌ្ឍគំរោងនេះ។

## ៥.៤.២ ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២

ការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ ត្រូវបានប្រារព្ធធ្វើឡើងនៅ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ នៅសាលប្រជុំសាលាខេត្តព្រះសីហនុ។

វេមាសភាពនៃអ្នកចូលរួមប្រជុំរួមមាន :-

(១) អាជ្ញាធរដែនដីក្នុងតំបន់គំរោងមាន ដូចជា មេភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ សមាគមន៍ ប៉ូលីស កងរាជអាវុធហត្ថ អភិបាលក្រុង មន្ត្រីសាលាខេត្ត ខុទ្ទកាល័យខេត្ត អភិបាលរងខេត្ត ប្រធានក្រុមប្រឹក្សាខេត្ត និងអភិបាលខេត្ត

(២) មន្ទីរជំនាញក្រោមឪវ៉ាទខេត្ត

(៣) តំណាងវិស័យឯកជន

(៤) អង្គការក្រៅរដ្ឋាភិបាលមួយចំនួន និង

(៥) មន្ត្រីតំណាងក្រសួងបរិស្ថាន។

ការរៀបចំអញ្ជើញ ស្ថាប័នក្រោមឪវ៉ាទខេត្តតាមរយៈខុទ្ទកាល័យសាលាខេត្ត ហើយចំពោះតំណាងក្រសួងពាក់ព័ន្ធពីភ្នំពេញមានលិខិតអញ្ជើញផ្ទាល់ពីក្រុមសិក្សា វ.ហ.ប។ កម្មវិធីប្រជុំពិស្តារ ឯកសារបទបង្ហាញ និងបញ្ជីឈ្មោះអ្នកចូលរួម មានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធទី ៧គ។

សកម្មភាពពិស្តារពីការប្រជុំ និងចំនួនអ្នកចូលរួមត្រូវបានរៀបរាប់ក្នុងតារាង៥.៤.២-១ និងតារាង៥.៤.២-២។

តារាង ៥.៤.២-១: សកម្មភាពពិស្តារសំរាប់កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២

| ម៉ោង | សកម្មភាព | កំណត់សំគាល់ |
|---|---|---|
| ២:០០-២:១៥ | ចុះឈ្មោះអ្នកចូលរួមប្រជុំ | |
| ២:១៥-២:១៨ | ប្រកាសរបៀបវារៈអំពីកម្មវិធីប្រជុំ និងភ្លេងជាតិ | ដោយ KCC |
| ២:១៨-២:២៥ | មតិស្វាគមន៍បើកកិច្ចប្រជុំ | នាយកគំរោង នៃក្រុមហ៊ុនកោះពស់ |
| ២:២៥-២:៣៥ | ចំណាប់អារម្មណ៍របស់គណៈអធិបតី/ប្រធានអង្គប្រជុំចំពោះ **គំរោងមរកត (អភិវឌ្ឍន៍កោះពស់ និងឆ្នេរកោះពស់)** | ដោយ ឯ.ឧ អភិបាលខេត្ត ព្រះសីហនុ |
| ២:៣៥-៣:៣០ | បទបង្ហាញអំពីលទ្ធផលនៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោង **គំរោងមរកត** | ដោយ KCC |
| ៣:៣០-៣:៤០ | សំរាកពិសាអាហារសំរន់ | |
| ៣:៤០-៥:០០ | ១- កិច្ចពិភាក្សា................. | |
| | ២- ការចូលរួមយោបល់ សំណូមពរកែលំអ និងសួរសំណួរ ពីសំណាក់ | |

| | | |
|---|---|---|
| | អ្នកចូលរួម។ ចំលើយតប កំណត់ត្រារាល់មតិយោបល់កែលំអ និងសំណួរផ្សេងៗ។ | |
| ៥:០០-៥:១៥ | ចំណាប់អារម្មណ៍បូកសរុបកិច្ចប្រជុំ និងបិទកម្មវិធី | ដោយ ឯ.ឧ អភិបាលខេត្ត ព្រះសីហនុ |

តារាង ៥.៤.២-២: ទីកន្លែង ពេលវេលា និងអ្នកចូលរួមប្រជុំពិគ្រោះយោបល់ជាសាធារណៈលើទី២

| កាលបរិច្ឆេទ | ទីកន្លែងប្រជុំ | ចំនួនអ្នកចូលរួម | | | | | |
|---|---|---|---|---|---|---|---|
| | | ស្ថាប័នរដ្ឋ | សមាគមន៍ | អង្គការក្រៅរដ្ឋាភិបាល | វិស័យឯកជន | ម្ចាស់គំរោង និងអ្នកសិក្សា | សរុប |
| ១៧ ធ្នូ ២០១០ | សាលប្រជុំសាលាខេត្តព្រះសីហនុ | ៣២ | ២ | ៤ | ៦ | ៥ | ៤៩ |

**សំគាល់:** ក្រុមសិក្សា២នាក់ និងម្ចាស់គំរោង៣នាក់ និងបញ្ជីឈ្មោះអ្នកចូលរួមមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធទី ៧គ

Draft

អង្គប្រជុំបានបង្ហាញពីលទ្ធផលនៃការសិក្សាសមទ្ធិលទ្ធភាពនៃគំរោងមរកត ព្រមទាំងបង្ហាញពីប្លង់វិស្វកម្ម និងទិដ្ឋភាពបរិស្ថាន យ៉ាងច្បាស់ដោយប្រើកម្មវិធីកំព្យូទ័រ in PowerPoint, words/excels, និងមានរូបភាពផែនទីក្នុងប្រព័ន្ធភូមិសាស្ត្រ GIS។ ធ្វើការប៉ាន់ប្រមាណទៅលើហេតុប៉ះពាល់របស់គំរោងក្នុងដំណាក់ការសាងសង់ និងប្រតិបត្តិការរបស់គំរោង រៀបចំវិធានការកាត់បន្ថយសំរាប់ផលប៉ះពាល់ជាអវិជ្ជមាននីមួយៗ។ សំណួរ ការពិភាក្សា និងយោបល់ផ្សេងៗ គឺអនុលោមទៅតាមដំណាក់ការនៃការបង្ហាញនីមួយៗ។ រាល់អនុសាសន៍ទាំងអស់ និងសំណួរត្រូវបានកត់ត្រាទុកដោយក្រុមសិក្សា ហើយសំណើ និងសំណួរមួយចំនួនធំត្រូវបានឆ្លើយតបភ្លាមៗ។ លទ្ធផលនៃអង្គប្រជុំមានរៀបរាប់នៅក្នុងតារាង ៥.៤.២-៣។

តារាង ៥.៤.២-៣: លទ្ធផលនៃអង្គប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២

| **ឈ្មោះ** | **មុខងារ និងស្ថាប័ន** | **គំនិតយោបល់ អនុសាសន៍ និងសំនួរ** |
|---|---|---|
| ឯកឧត្តម ស្បោង សារ៉ាត | អភិបាលខេត្ត ព្រះសីហនុ | ជាបឋមឯកឧត្តមបានទទួលស្វាគមន៍ទៅដល់អង្គប្រជុំទាំងមូល ជាពិសេសប្រធានក្រុមហ៊ុនកោះពស់ លោកលោកស្រីដែលបាន ចូលរួមក្នុងពិធីប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២នេះ ដោយសេចក្តីរីករាយជាទីបំផុត ។ តាងនាមឱ្យអាជ្ញាធរដែនដី និងរូបលោកផ្ទាល់លោកសូមធ្វើការគាំទ្រ និងវាយតំលៃខ្ពស់ទៅលើគំរោងមរកតនេះ ព្រោះអ្វីៗដែលបានកសាងឡើងនេះ គឺដើម្បីបង្កើនសេដ្ឋកិច្ចជាតិក៏ដូចជាបង្កើនប្រាក់ចំណូលប្រចាំ គ្រួសារដោយបង្កើនការងារជូនទៅដល់ប្រជា |

| | | |
|---|---|---|
| | | ពលរដ្ឋ។ ជាងនេះទៅទៀត ជាក់ស្តែងសមទ្ធិផលនានាមានដូចជាផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងថ្មីៗនេះគំរោងបានសាងសង់ស្ពានកោះពស់ ទាំងអស់នេះ គឺដើម្បីជំរុញវិស័យទេសចរណ៍ និងប្រាក់ចំណូលដល់ សេដ្ឋកិច្ចជាតិទាំងមូល។ |
| លោក បូន ណារិទ្ធ | បុគ្គលិកអង្គការលីកាដូ | សូមគោរព ឯកឧត្តម លោក លោកស្រី ដែលបានចូលរួមក្នុងពិធីប្រជុំពិគ្រោះយោបល់អំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាននៅថ្ងៃនេះ។ ខ្ញុំបានមើលបទបង្ហាញរបស់ក្រុមសិក្សាឃើញថាមាន លក្ខណៈល្អប្រសើរគ្រប់គ្រាន់ហើយ បានឃើញការពន្យល់អំពីការតភ្ជាប់ទឹកស្អាត និងអគ្គិសនីពីក្រុង។ ប៉ុន្តែឃើញមានចំនុចខ្វះខាតខ្លះៗ និងនៅមានចម្ងល់ខ្លះៗដូចតទៅ:<br>- តើទឹកបំអុយ និងកាកសំណល់រឹងត្រូវបង្ហូរចោលទៅទីណា?<br>- ចំពោះចំនួនកម្មករមានចំនួន ៧៥០ ទៅ ១០០០នាក់ តើរៀបចំប្រព័ន្ធអនាម័យក្នុងការបញ្ចេញចោលនូវកាកសំណល់យ៉ាងដូចម្តេច នៅក្នុងរយៈពេលសាងសង់?<br>- តើគំរោងនេះបង់ពន្ធជូនរដ្ឋចំនួនប៉ុន្មានក្នុងមួយឆ្នាំ?<br>**<u>សំណូមពរ :</u>**<br>• សូមឱ្យគ្រប់គ្រងប្រព័ន្ធទឹកសំអុយឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសមុននឹងបង្ហូរចេញទៅក្រៅ។<br>• មិនត្រូវធ្វើអាងចំរោះទឹកស្អាត និងទឹកស្អុយនៅជិតគ្នាទេ ព្រោះវាអាចនឹងមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់ ក៏ដូចជាភ្ញៀវទេសចរណ៍មកលេងនៅក្បែរៗនេះ។<br>• សូមគ្រប់គ្រងការបញ្ចេញកាកសំណល់ពីផ្ទះ និង សណ្ឋាគារឱ្យបានត្រឹមត្រូវបំផុត ព្រោះលំនៅដ្ឋាន និង សណ្ឋាគារសព្វថ្ងៃនេះកាន់តែច្រើន ធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្សជាមិនខាន។ |
| លោក Andrew Halturin | នាយកគំរោង នៃក្រុមហ៊ុនកោះពស់អ៊ិនវេសមេនគ្រុប | យើងនឹងធ្វើការសាងសង់លើកោះនេះឱ្យបានល្អឥតខ្ចោះតែម្តង យើងសង់ជាលក្ខណៈស្តង់ដា លំនៅដ្ឋានទំនើប សណ្ឋាគារ គឺចាប់ពីផ្កាយបួនឡើងទៅ។ គោលបំណងនៃការសាងសង់ គឺទាញយកភ្ញៀវទេសចរណ៍ ក៏រិតខ្ពស់ឱ្យបានច្រើន ពេលនោះ គឺមានផលប្រយោជន៍ជាច្រើន ដល់រដ្ឋាភិបាលកម្ពុជា។<br>ក្រុមហ៊ុនយើងខ្ញុំយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការបញ្ចេញចោលនូវកាកសំណល់ ហើយធ្វើយ៉ាងណាឱ្យមានជាសុខភាព។ ដូចនេះហើយបានជាក្រុមហ៊ុនយើងខ្ញុំធ្វើការសំអាតមុននឹងបញ្ចេញចោលទៅសមុទ្រ ហើយធ្វើយ៉ាងណាឱ្យមានលក្ខណៈស្តង់ដា។ ចំពោះកាកសំណល់រឹងវិញ យើងមានកន្លែងប្រមូលផ្តុំ ហើយយកទៅចោលនៅកន្លែងផ្សេង តាមរយៈក្រុមហ៊ុនប្រមូលសំរាម CINTRI សាខាក្រុងព្រះសីហនុ។ |

Draft

| | | |
|---|---|---|
| | | ការសាងសង់នៅលើកោះពស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យបន្ទោបង់នៅលើកោះទេ ក្រុមហ៊ុនកោះពស់បន្តសហការជាមួយដៃគូអភិវឌ្ឍន៍ និងគណ:កម្មការសាងសង់ និងមានវិធានការទប់ស្កាត់ នូវការបញ្ចេញកាកសំណល់រឹង រាវ និងធ្វើការគ្រប់គ្រងឱ្យបានហ្មតចត់ ហើយនឹងធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់ ។ ខ្ញុំគិតថា កោះពស់គឺជាគ្រាប់ពេជ្រមួយ ខ្ញុំមិនចង់ឱ្យគេបំផ្លាញវាទេ ។ |
| លោក តាំង សុផាន់ណារ៉ា | ប្រធានក្រុមសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ក្រុមហ៊ុន KCC | ខ្ញុំសូមឆ្លើយបន្ថែមតបចំពោះសំណួររបស់បុគ្គលិកអង្គការលីកាដូ ដូចតទៅ:-<br>- គំរោងមរកតបានរៀបចំប្លង់ អាងប្រព្រឹត្តកម្មដើម្បីសំអាតទឹកក្រខ្វក់ ទាំងនៅលើកោះពស់ និងនៅឆ្នេរហាវ៉ៃ ដែលមានទំហំ និងសមត្ថភាពធានាការសំអាតតាមគុណភាពស្តង់ដាបង្ហូរចេញរបស់ក្រសួងបរិស្ថាន ( សូមមើលរូប និងការពិព័ណ៌នាក្នុងរបាយការណ៍ វ.ហ.ប) ។<br>- ចំពោះសំរាមរឹង ក្រុមហ៊ុនកោះពស់បានប្រើប្រាស់ និងបន្តការប្រើប្រាស់សេវាកម្មប្រមូលសំរាមរបស់ក្រុមហ៊ុន CINTRIសាខាក្រុងព្រះសីហនុ ។<br>- បង្គន់អនាម័យនឹងត្រូវសាងសង់ឱ្យបានសមស្របតាមចំនួនបុគ្គលិកកម្មករតាមរយ:កិច្ចសន្យាជាមួយក្រុមហ៊ុនសាងសង់ ។<br>- ការបង់ពន្ធជាជូនរដ្ឋ គឺយោងតាមកតព្វកិច្ចច្បាប់ និងកិច្ចសន្យាវិនិយោគរវាងរាជរដ្ឋាភិបាល ជាមួយក្រុមហ៊ុន ។ |
| លោក ច័ន្ទ ចំរើន | បុគ្គលិកអង្គការអាដហុក | ជាបឋមខ្ញុំសូមកោតសរសើរដល់ក្រុមហ៊ុនដែលបាននិយាយពាក្យថា ស្តង់ដា ហើយសូមសរសើរដល់ក្រុមហ៊ុនដែលបានរៀបចំកិច្ចប្រជុំនេះ ហើយសូមអរគុណដល់ក្រុមហ៊ុនវិនិយោគក្នុងប្រទេសកម្ពុជា និងក្នុងខេត្តព្រះសីហនុយើងដែលជាមុខមាត់ក្នុងខេត្តយើងផ្ទាល់ ក៏ដូចប្រជាពលរដ្ឋខ្មែរយើងទាំងមូលដើម្បីកាត់បន្ថយភាពក្រីក្រ ។ ខ្ញុំមានសំណួរពីរ:<br>- តើក្រុមហ៊ុនឃីខនសាល់ធេន ដែលជាក្រុមហ៊ុនសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងមរកតនេះមកពីស្ថាប័នណា ?<br>- តើបានសហការជាមួយភាគីពាក់ព័ន្ធពីរាជរដ្ឋាភិបាលដូចជា ក្រសួងបរិស្ថានចូលរួមក្នុងការវាយតំលៃហេតុប៉ះពាល់បរិស្ថាននេះដែរឬទេ? ឬក៏ក្រុមហ៊ុនឃីខនសាល់ធេននេះ ធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានតែឯង ?<br>ចុងបញ្ចប់ខ្ញុំសូមសំណូមពរក្រុមហ៊ុនមកធ្វើវិនិយោគឱ្យបានច្រើន ហើយចង់ឱ្យក្រុមហ៊ុនវិនិយោគគួរតែយកគំរូតាមរបៀបនេះ ។ ក្នុងនាមខ្ញុំជាប្រជាពលរដ្ឋខ្មែរ សូមឱ្យក្រុមហ៊ុនវិនិយោគទាំងអស់ធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានច្បាស់លាស់ មុននឹងអនុវត្តន៏គំរោង ។ |

Draft

| | | |
|---|---|---|
| លោក តាំង សុផាន់ណារ៉ា | ប្រធានក្រុមសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់ក្រុមហ៊ុន KCC | ខ្ញុំសូមឆ្លើយតបចំពោះសំណួររបស់បុគ្គលិកអង្គការអាដហុក ដូចតទៅៈ-<br>- ក្រុមហ៊ុនឃី ខនសាល់ធេន KCC យើងខ្ញុំជាក្រុមហ៊ុនក្នុងស្រុកស្របច្បាប់មួយដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងបានទទួលលិខិតអនុញ្ញាតក្នុងការសិក្សាស្រាវជ្រាវរៀបចំ និងចងក្រងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ពីក្រសួងបរិស្ថាន ។<br>- យោងតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន រាល់របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានទាំងអស់ត្រូវដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងវាយតំលៃដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ចំណែកការសិក្សាស្រាវជ្រាវចងក្រងរបាយការណ៍ វ.ហ.ប ដោយក្រុមហ៊ុន KCC គឺមានភាពឯករាជ្យ និងពុំមានការកៀបសង្កត់ពីស្ថាប័ន ឬផ្នែកណាមួយនោះទេ ។ |
| លោក ប្រាក់ ស៊ីហារ៉ា | អភិបាលរងខេត្ត ខេត្តព្រះសីហនុ | សូមគោរពឯកឧត្តមអភិបាលខេត្ត ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត លោកនាយកគំរោងមរកត ដែលបានមកពិភាក្សាពិគ្រោះយោបល់វាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងមរកតនៅពេលនេះ ខ្ញុំចង់លើកឡើងទៅម្ចាស់គំរោងអំពីបញ្ហាសេដ្ឋកិច្ច និងការអនុវត្ត ខ្ញុំយល់ថាខេត្តព្រះសីហនុយើងនេះសំខាន់ណាស់លើសក្តានុពលទេសចរណ៍ ហើយដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិ ថ្ងៃនេះយើងបានធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានលើគំរោងមរកតយើងនេះ ។ ខ្ញុំចាប់អារម្មណ៍លើក្រុមហ៊ុន KCC បានលើកឡើងថាជារបាយការណ៍ពេញលេញដែលកំពុងសិក្សាឆ្លងការពិគ្រោះយោបល់ថ្នាក់ខេត្ត បន្ទាប់មកទៅឆ្លងថ្នាក់ក្រសួងជាបន្តទៀត ដូចនេះយើងគួរកែទទួលយក ។<br>ខ្ញុំចាប់អារម្មណ៍ លើSlideទី២៣ដែលលើកឡើងតែ កាកសំណល់រឹង ប៉ុន្តែកាកសំណល់រាវមិនបានឃើញទេ ដូចនេះសូមសំណូមពរឱ្យដាក់បញ្ហាគ្រប់គ្រងសំណល់រាវក្នុងបទបង្ហាញទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស ។ ម្យ៉ាងវិញទៀត ការសរសេរនិងកាអនុវត្តមិនដូចគ្នាទេ អញ្ចឹងហើយត្រូវយកចិត្តទុកដាក់ទៅលើចំណុចនៃការគ្រប់គ្រងកាកសំណល់នេះ ។ ចំណុចមួយទៀតបញ្ហាកករដីនៅពេលធ្វើការឈូសឆាយនឹងមានការហូរចូល ទៅក្នុងសមុទ្រធ្វើឱ្យប៉ះពាល់ដល់ជីវចំរុះសមុទ្រ ។<br>ចុងក្រោយនេះ ខ្ញុំសូមអរគុណដល់ក្រុមហ៊ុនកោះពស់ដែលបានយកចិត្តទុកដាក់ជាងគេក្នុងចំណោមក្រុមហ៊ុនទាំង២៦ដែលបានធ្វើការអភិវឌ្ឍនៅក្នុងខេត្តព្រះសីហនុ ។ |
| លោក Halturin Andrew | នាយកគំរោង នៃក្រុមហ៊ុនកោះពស់ | ក្រុមហ៊ុនយើងខ្ញុំនឹងធ្វើយ៉ាងណាមិនឱ្យមានកំហុសបច្ចេកទេសទេ បច្ចុប្បន្ននេះយើងក៏ធ្វើការជាមួយក្រុមហ៊ុនសាងសង់ស្ពានកោះពស់ដែរ ដែលមានកម្មករចំនួន |

Draft

| | | |
|---|---|---|
| | អ៊ិនវេសមេនគ្រុប | ២០០នាក់ ហើយយើងគ្រប់គ្រងបានយ៉ាងល្អ ចំពោះកាកសំណល់រឹង និងសំណល់រាវ ។<br>ក្រុមហ៊ុននឹងជ្រើសរើសរកក្រុមហ៊ុនដែលមានលក្ខណៈស្តង់ដាជា ក្រុមហ៊ុនដែលធំជាងគេនៅក្នុងខេត្តព្រះសីហនុជាដៃគូររបស់យើង ។ យើងខ្ញុំសុទ្ធតែបុគ្គលិកដែលមានជំនាញ និងបទពិសោធន៍ខ្ពស់ ដូចជា លោកស៊ូ អ៊ីន គាត់ជាវិស្វករធ្លាប់សាងសង់នៅអូរឡាំពិកនោះជាបុគ្គលិករបស់ក្រុមហ៊ុនយើងខ្ញុំដែរ ហើយក៏មានបទពិសោធន៍ជាច្រើនទៀតក្នុងការសាងសង់ ដូចជានៅក្នុងប្រទេសរុស្ស៊ី ទួគី ញូយ៉ក និងប្រទេសអេស្ប៉ាញ ។ ដូច្នេះការអភិវឌ្ឍតំបន់នេះ គឺមិនធ្វើឱ្យមានផលប៉ះពាល់នោះទេ ។<br>សូមជឿជាក់មកលើក្រុមហ៊ុនយើងខ្ញុំចុះ ខ្ញុំនឹងរកដៃគូសាងសង់ និងធ្វើកិច្ចសន្យាដើម្បីគ្រប់គ្រងកាកសំណល់រឹង និងរាវឱ្យបានល្អ ប្រសិនបើក្រុមហ៊ុនសាងសង់មិនគោរពតាមកិច្ចសន្យា យើងនឹងធ្វើការពិន័យឬបញ្ចប់កិច្ចសន្យាសាងសង់តែម្តង ។<br>សូមអរគុណយ៉ាងជ្រាលជ្រៅចំពោះមតិយោបល់ទាំងអស់នេះ ។ |
| លោក សូ សុខ | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តព្រះសីហនុ | ដោយលើកឡើងពីកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ លើការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងមរកតនេះ ខ្ញុំសូមគាំទ្រទាំងស្រុង ។ ហើយគំរោងអភិវឌ្ឍន៍កោះពស់ ឬកោះមរកតនេះបានគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជាយើងផងដែរ ។ តែអ្វីដែលខ្ញុំចង់លើកមកជំរាបជូនលោកនាយកគំរោង និងអង្គប្រជុំទាំងមូលគឺការបំពេញបែបបទសំរាប់ការកាន់កាប់ដីជួលនៃទីតាំងអនុវត្តគំរោងឱ្យសមស្របតាមនិតិវិធីនៃច្បាប់ ។ កន្លងមកក្រុមហ៊ុនកោះពស់នេះ បានបំពេញបែបបទបានចំនួនពីរក្បាលដីជួលហើយ គឺនៅសល់តែមួយក្បាលដីទៀតទេ ។<br>ខ្ញុំសំណូមពរឱ្យក្រុមហ៊ុនសហការជាមួយមន្ទីរជំនាញ ដើម្បីជំរុញការបំពេញបែបបទឱ្យបានសព្វគ្រប់តាមនិតិវិធីនៃច្បាប់ភូមិបាល ។ |
| ឯកឧត្តម ស្បោង សារ៉ាត | អភិបាលខេត្តព្រះសីហនុ | ជាទីបញ្ចប់ខ្ញុំសូមធ្វើការបូកសរុបដើម្បីបញ្ចប់កម្មវិធី ឆ្លងតាមរយៈកិច្ចប្រជុំនេះការចូលរួមផ្តល់មតិយោបល់ និងសំនូរមួយចំនួន ហើយលោកនាយកក្រុមហ៊ុនមរកត និងក្រុមហ៊ុន KCC ដែលជាអ្នកសិក្សាបានជំរាបជូន និងធ្វើការបកស្រាយអំពីការអភិវឌ្ឍនេះបានយ៉ាងក្បោះក្បាយ ហើយខ្ញុំសូមសរុបឡើងវិញនូវបញ្ហាទាំងអស់គឺភាពលក្ខណៈល្អប្រសើរណាស់សំរាប់បទពិសោធន៍របស់យើង ហើយក៏សំរាប់ក្រុមហ៊ុនវិនិយោគក្នុងខេត្តរបស់យើងទាំងអស់ផងដែរ ។ តាមការតាមដានរបស់ខ្ញុំអំពីអង្គប្រជុំនេះ ខ្ញុំសូមចូលរួម២ចំណុចដូចខាងក្រោមៈ<br>**<u>ចំណុចទី១</u> :** សូមថ្លែងអំណរគុណចំពោះក្រុមហ៊ុនកោះពស់ និងសហការី ដែលបានជំរាបជូនអំពីលទ្ធផលនៃការអនុវត្តគំរោង សាងសង់ស្ពានកោះពស់ ក៏ដូចជាការអភិវឌ្ឍផ្នែកដទៃទៀតនៅលើកោះពស់ និងឆ្នេរហាវ៉ៃ ។ គំរោងនេះក៏ជាកិត្តិយសរបស់យើង ដែលបានឃើញនូវការរីកចំរើននាពេលខាងមុខនេះលើតំបន់កោះពស់ ។ |

Draft

<table>
<tr><td></td><td></td><td>ហើយក៏មានអង្គការមិនមែនរដ្ឋាភិបាល ដូចជា អាដហុក ដែលបានចូលរួមលើកជាមតិយោបល់ និងគាំទ្រ អញ្ចឹងហើយអ្វីៗដែលបានលើកឡើង គឺល្អណាស់នេះជាមុខមាត់របស់ខេត្តយើងដែរក្នុងរយៈពេលពី១០ ទៅ១៥ឆ្នាំទៀតយើងនឹងឃើញការអភិវឌ្ឍរីកចំរើននៅក្នុងខេត្តនេះ។<br><br><u>ចំណុចទី២:</u> សូមក្រុមហ៊ុនអនុវត្តន៏គំរោងទៅតាមការព្រួយបារម្ភដែលបានលើកឡើងជុំវិញបរិស្ថាន។ យើងក៏សូមស្នើ អាជ្ញាធរគ្រប់លំដាប់ថ្នាក់បន្តជួយបង្កលក្ខណៈងាយស្រួល ដើម្បីឱ្យក្រុមហ៊ុនអភិវឌ្ឍន៏មានការកក់ក្តៅមកលើយើង ហើយសំណូមពរឱ្យក្រុមហ៊ុនធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ហើយមានអនុគណៈកម្មការវិនិយោគខាងខេត្តមួយ ដើម្បីត្រួតពិនិត្យការសាងសង់ និងត្រួតពិនិត្យគំរោងវិនិយោគផ្សេងៗទៀត ។ សំណូមពរឱ្យក្រុមហ៊ុននេះធ្វើយ៉ាងណាឱ្យមានសោភ័ណ្ឌភាព។ ជាថ្មីម្តងទៀត យើងខ្ញុំសូមអរគុណក្រុមហ៊ុនកោះពស់ ដែលបានរៀបចំនូវអង្គប្រជុំដើម្បីធ្វើការប្រមូលទិន្នន័យ ក៏ដូចជាមតិយោបល់ អំពីការព្រួយបារម្ភ និងកង្វល់ផ្សេងពីអ្នកដែលពាក់ព័ន្ធទាំងឡាយ។ សង្ឃឹមថា ក្រុមហ៊ុនកោះពស់នេះនឹងមិនធ្វើឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរណាមួយទេ ហើយគំរោងទាំងមូលនឹងមានគុណភាព និងសោភ័ណ្ឌភាពល្អឥតខ្ចោះ។ សូមប្រកាសរំសាយ ។</td></tr>
<tr><td colspan="3">សំណួរទាំងអស់ត្រូវបានឆ្លើយតបដោយក្រុមសិក្សា វ.ហ.ប និងនាយកគំរោងមរកត។<br>អ្នកចូលរួមទាំងអស់បានកោតសរសើរចំពោះបទបង្ហាញលទ្ធផលយ៉ាងច្បាស់នៃការសិក្សា និងបានឆ្លើយតបយ៉ាងច្បាស់លាស់ទៅនឹងសំណួរ និងចម្ងល់ផ្សេងៗ។ អ្នកចូលរួមទាំងអស់បានសំដែងការគាំទ្រលើការអភិវឌ្ឍគំរោងមរកតនេះទាំងស្រុង។</td></tr>
</table>



រូបភាព ៥.៤.២-១: សកម្មភាពកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២

Draft

## ៥.៤.៣ ការជួបប្រជុំជាមួយអ្នកដែលពាក់ព័ន្ធ

ស្ថាប័នពាក់ព័ន្ធសំខាន់ៗមួយចំនួនមានៈ ស្ថាប័នរដ្ឋាភិបាល ដូចជា នាយកដ្ឋាន និងមន្ទីរពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន និងផ្នែកឯកជន ត្រូវបានជួបប្រជុំពិភាក្សា និងពិគ្រោះ យោបល់ នៅក្នុងអំឡុងពេលនៃការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោង**មរកត**របស់ក្រុមហ៊ុន កោះពស់ (ខេបូឌា) អ៊ិវេសមេនគ្រុប ។

តារាង ៥.៤.៣-១: លទ្ធផលនៃកិច្ចប្រជុំ និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ

| ថ្ងៃ ខែ ឆ្នាំ | ឈ្មោះអ្នកចូលរួម | មុខងារ និង ស្ថាប័ន | គំនិត យោបល់ និងសំណួរ |
|---|---|---|---|
| ០៨/៦/២០០៩ | លោក ហែម សាវឿន | ប្រធានមន្ទីរបរិស្ថាន ខេត្តព្រះសីហនុ | ខ្ញុំបានឮគំរោងអភិវឌ្ឍន៍កោះពស់ឬមរកតនេះដែរ កាលពីឆ្នាំទៅ ។ ដោយសារតែទីតាំងគំរោង នឹងមិនធ្វើឱ្យមានផលប៉ះពាល់ទៅដល់ដីប្រើប្រាស់របស់សហគមន៍ និងតំបន់អភិរក្សជុំវិញតំបន់គំរោងនោះទេ ។ ដីកោះពស់ គឺជាកោះដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ គ្មានអ្នកណាម្នាក់មានសិទ្ធិកាន់កាប់ដីនេះបានទេ ។<br>ខ្ញុំគិតថាគំរោងនេះនឹងមានផលប៉ះពាល់ទៅដល់ធនធានធម្មជាតិនៅក្នុងតំបន់ ដូច្នេះតំរូវឱ្យមានការសិក្សាអំពីការវាយតំលៃហេតុប៉ះពាល់បរិស្ថានឱ្យបានត្រឹមត្រូវ ។ តំបន់គំរោងនេះ គឺមានលក្ខណៈតូចប៉ុន្តែបែរជាសកម្មភាពសាងសង់រចនាសម្ព័ន្ធច្រើនដោយមានអាគារខ្ពស់ៗ ។<br>លោកបានស្នើទៅម្ចាស់គំរោងឱ្យរៀបចំវិធានការកាត់បន្ថយឱ្យបានត្រឹមត្រូវ និងសមរម្យលើចំណុចសំខាន់ៗមានដូចជា:<br>• ការបំពុលទឹក<br>• ប្រព័ន្ធលូបង្ហូរទឹក<br>• កាកសំណល់រឹង ។ |
| ០៨/៦/២០០៩ | លោក ស៊ុត ចាន់ថន | នាយរងខុទ្ទកាល័យ សាលាខេត្តព្រះសីហនុ | លោកបានមានប្រសាសន៍ថា ដើម្បីគ្រប់គ្រងទីតាំងនេះឱ្យបានល្អ ត្រូវបែងចែកតំបន់នេះជាតំបន់តូចៗ ប៉ុន្តែវាអាស្រ័យទៅលើគោលការណ៍ណែនាំ និងច្បាប់របស់រដ្ឋាភិបាល ។ លោកបាន រំលឹកថានៅពេលក្រុមការងារចុះប្រជុំ ឬសំភាសន៍តាមផ្ទះប្រជាជន |

| | | | |
|---|---|---|---|
| | | | គួរតែមានគ្រឿងលើកទឹកចិត្តដល់ពួកគាត់ដើម្បីឱ្យការងាររលូន។ លោកមានការព្រួយបារម្ភអំពីវិបត្តិសេដ្ឋកិច្ចពិភពលោកអាចជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសកម្ពុជា ជាពិសេសវិស័យទេសចរណ៍។<br>ទន្ទឹមនេះដែល លោកបានសំណូមពរឱ្យ ក្រុមហ៊ុនវិនិយោគត្រូវគោរពតាមកិច្ចសន្យាជាមួយរដ្ឋាភិបាល និងត្រូវមានទំនាក់ទំនងការងារឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរដែនដី និងមន្ទីរនានា។<br>ចុងក្រោយនៃកិច្ចពិភាក្សាលោកបានយល់ព្រមលើគំរោង១០០% និងសន្យាសហការ និងសំរបសំរួលនូវរាល់ការងារដែលពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុនកោះពស់នេះ។ គំរោងនេះ នឹងផ្តល់ឱ្យមានការងារធ្វើច្រើនទៅដល់ប្រជាជននៅក្នុងខេត្តព្រះសីហនុ និងបង្កើនប្រាក់ចំណូល។ |
| ០៩/៦/២០០៩ | លោក ជួន ចាន់ពិសិទ្ធ | មន្ត្រីមន្ទីរអប់រំខេត្តព្រះសីហនុ | លោកបានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងគាំទ្រទៅលើគំរោងនេះ ព្រោះចំណេញច្រើនណាស់ដល់សេដ្ឋកិច្ចជាតិ ហើយលោកបានសំណូមពរដល់ម្ចាស់គំរោងឱ្យគោរពទៅតាមផែនការមេ ប៉ុន្តែលោកមានការព្រួយបារម្ភទៅលើការបំពុលទឹកនៅក្នុងអំឡុងពេលធ្វើការសាងសង់គំរោង។ |
| ០៩/៦/២០០៩ | លោក សោម ចិន្តា | ប្រធានមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ | នៅក្នុងជុំវិញតំបន់គំរោងនេះមិនទាន់មានសមាគមទេសចរណ៍ធម្មជាតិនៅឡើយទេ ប៉ុន្តែមានសក្តានុពលសំរាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ដូចជា តំបន់ឆ្នេរដ៏ស្រស់ស្អាត កោះជាច្រើន ព្រៃធម្មជាតិ ឧទ្យានជាតិ, និងទឹកធ្លាក់(ក្បាលឆាយ)។ ក្រៅពីនេះមានវត្តអារ៉ាម៣ទៀត ដែលជាធនធានវប្បធម៌ហើយកន្លងមកមានភ្ញៀវបរទេស ក៏ដូចជាភ្ញៀវក្នុងស្រុកចូលចិត្តទស្សនាតំបន់នេះជារៀងរាល់ថ្ងៃភ្ញៀវទាំងនោះមកទីនេះដើម្បី ទស្សនា និងសិក្សាស្រាវជ្រាវវប្បធម៌ខ្មែរ។ ក្នុងឆ្នាំ២០០៨ មានភ្ញៀវទេសចរណ៍សរុប ៥៣២.៥១៨ នាក់ បានមកទស្សនាក្រុងព្រះសីហនុនេះ ក្នុងនោះភ្ញៀវអន្តរជាតិមាន ១៣៥.៦៦៨ នាក់ ភាគច្រើនចូលតាមច្រកនាវាទេសចរណ៍អន្តរជាតិ។ ប៉ុន្តែពាក់កណ្តាល ឆ្នាំ២០០៩ ភ្ញៀវសរុប ៣៣៤.១១០ នាក់ ចូលទស្សនាក្នុងខេត្តព្រះសីហនុ ក្នុងនោះភ្ញៀវអន្តរជាតិ ៧៤.៣៩២ នាក់ ។<br>កន្លងមកមានអង្គការមួយចំនួន ដូចជា (ILO, IPEC, WVC) បានជួយលើផ្នែកវិស័យទេសចរណ៍នេះ ដោយមានការផ្សព្វផ្សាយ និងបណ្តុះបណ្តាល អំពីសេវាកម្មបំរើភ្ញៀវ ជាពិសេសជួយទប់ស្កាត់ការជួញដូរស្ត្រី និងកុមារនៅក្នុងតំបន់។ ជាការពិតណាស់ |

| | | | |
|---|---|---|---|
| | | | រាល់គំរោងអភិវឌ្ឍន៍តែងតែមានផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាន ប៉ុន្តែយើងមិនអាចដឹងច្បាស់ទេប្រសិនបើយើងគ្រាន់តែមើលដោយមិនបានវិភាគឱ្យបានស៊ីជំរៅនោះទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ លោកគិតថាអ្វីៗនឹងត្រូវបានដោះស្រាយជាជំហានៗដោយគោរពតាមបទដ្ឋានវិទ្យាសាស្ត្រ ។<br>ទាក់ទងទៅនឹងគំរោង**មរកត**នេះ លោកបានដឹងគំរោងនេះជាង១ឆ្នាំមកហើយដែរ ដែលបានយល់ព្រមដោយរដ្ឋាភិបាល ព្រោះគំរោងនេះមានសារៈសំខាន់ណាស់ ឧទាហរណ៍ ដូចជាការសាងសង់ស្ពានកោះពស់ តភ្ជាប់ពីដីគោកទៅកោះជាមួយរចនាសម្ព័ន្ធជាច្រើនត្រូវបានគេសាងសង់នៅលើកោះពស់ និងមានការអភិវឌ្ឍឆ្នេរហាវ៉ៃ ។ យើងស្វាគមន៍ និងគាំទ្រគំរោងនេះទាំងស្រុង ព្រោះគំរោងនេះ គឺជាឧស្សាហកម្មគ្មានផ្សែង និងស្មើទៅម្ចាស់គំរោង ដូចខាងក្រោម:<br>- ពន្លឿនការសាងសង់គំរោងកាន់តែឆាប់ កាន់តែល្អ ។<br>- ជួយផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជាទៅកាន់ពិភពលោកទាំងមូល ។<br>- បន្តសហការជាមួយមន្ទីរទេសចរណ៍ ទាំងហិរញ្ញវត្ថុ និងសំភារៈ ។<br>- ផ្តល់អាទិភាពការងារទៅដល់ប្រជាជន មូលដ្ឋានដើម្បីបានធ្វើការនៅក្នុងគំរោងនេះផង ។ |
| ០៩/៦/២០០៩ | លោក ខឹម សារ៉ុន | ប្រធានមន្ទីរសុខាភិបាលខេត្តព្រះសីហនុ | នៅក្នុងខេត្តព្រះសីហនុទាំងមូលមានមណ្ឌលសុខភាព ចំនួន ១០ប៉ុណ្ណោះ ។ ទាក់ទងទៅនឹងសកម្មភាពអភិវឌ្ឍន៍របស់គំរោងនៅក្នុងតំបន់ លោកមានការព្រួយបារម្ភអំពីបញ្ហា គ្រឿងញៀនការជួញដូរស្ត្រី និងកុមារ ការឆ្លងជំងឺអេដស៍ ហើយដែលនឹងត្រូវចាត់វិធានការដើម្បីស្វែងរកដំណោះស្រាយ ។<br>លោកបានស្វាគមន៍ និងគាំទ្រនូវគំរោងនេះទាំងស្រុង និងបានសន្យាថានឹងធ្វើសហប្រតិបត្តិការល្អជាមួយក្រុមហ៊ុនអនុវត្តគំរោង ។ លោកមានចំណាប់អារម្មណ៍ទៅលើផែនទីគំរោង និងព័ត៌មានគំរោងដែលបានផ្តល់ឱ្យដោយក្រុមពិគ្រោះយោបល់ (KCC) បង្ហាញថាគំរោងនឹងធ្វើការអភិវឌ្ឍមិនត្រឹមតែស្ពានកោះពស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀតនៅលើកោះពស់ និងឆ្នេរហាវ៉ៃ ។ លោកបានបញ្ជាក់ថា លោកសប្បាយចិត្តណាស់នៅពេលឃើញផែនការមេរបស់គំរោង ដែលរួមមានការសាងសង់មន្ទីរពេទ្យ "ប៉ូលីក្លីនិក" និងអាគារសាធារណៈផ្សេងទៀត ដែលមានការពាក់ព័ន្ធ ទៅនឹងសេវាសុខភាពសាធារណៈ ។ |

| | | | |
|---|---|---|---|
| | | | លោកបានស្នើទៅក្រុមហ៊ុនអនុវត្តគំរោង សូមឱ្យគ្រប់គ្រងកាកសំណល់ឱ្យបានល្អនៅក្នុងអំឡុងពេល និងបន្ទាប់ពីការសាងសង់ និងត្រូវរៀបចំប្រព័ន្ធរំដោះទឹកឱ្យបានត្រឹមត្រូវផងដែរ ពីព្រោះកាកសំណល់មន្ទីរពេទ្យ គឺពាក់ព័ន្ធយ៉ាងខ្លាំងទៅ នឹងសុខភាពសាធារណៈ ឬក៏វាអាចរាលដាលជំងឺទៅតំបន់ផ្សេងទៀត ដូច្នេះយើងត្រូវតែមានគំនិតផ្តួចផ្តើមបង្កើតឡដុតសំរាមពិសេស ហៅថា (C Sim) ។ លោកបានស្នើទៅក្រុមហ៊ុនអនុវត្តគំរោង ត្រូវចាត់វិធានការសកម្មភាពទប់ស្កាត់រោគជាមុន នៅតាមមន្ទីរព្យាបាល "ប៉ូលីគ្លីនិក" ដោយផ្តល់ធុងដាក់សំរាមដែលបែងចែកកាកសំណល់តាមប្រភេទខុសៗគ្នា ។<br>ទោះជាយ៉ាងណាក៏ដោយ គំរោងនេះអាចមានផលប៉ះពាល់ទៅដល់គុណភាពទឹកសមុទ្រ និងធនធានត្រីនៅក្នុងតំបន់កោះពស់ ដូច្នេះ តាងនាមឱ្យមន្ទីរសុខាភិបាលខេត្ត ខ្ញុំសំណូមពរទៅដល់ក្រុមហ៊ុនអនុវត្តគំរោងនូវចំនុចមួយចំនួនខាងក្រោម:<br>• ក្នុងការសាងសង់ប៉ូលីគ្លីនិចនៅលើកោះពស់ គឺត្រូវតែធ្វើការសហការជាមួយក្រសួងសុខាភិបាល<br>• ចាត់ចែងគ្រប់គ្រងរាល់កាកសំណល់ទាំងអស់ដែលបង្កើតចេញពីគំរោងឱ្យបានត្រឹមត្រូវ និងសមរម្យ<br>• ត្រូវមានសហប្រតិបត្តិការល្អជាមួយនឹងស្ថាប័នរដ្ឋាភិបាល និង<br>• បំពាក់ប្រព័ន្ធកែច្នៃកាកសំណល់ដើម្បីប្រើប្រាស់ឡើងវិញ ។ |
| ០៩/៦/២០០៩ | លោក សូ សុក | ប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី | លោកបានដឹងថា ដីកោះពស់នេះជាទ្រព្យសម្បត្តិ របស់រដ្ឋដែលបានធ្វើកិច្ចសន្យាជួល ចំនួន៩៩ឆ្នាំ ទៅឱ្យក្រុមហ៊ុនកោះពស់ចាប់តាំង ពីឆ្នាំ២០០៦មកម្ល៉េះ ។ ទន្ទឹមនោះដែរ ដីទីតាំងគំរោងឆ្នេរហាវ៉ៃ គឺជាដីឯកជនរបស់រដ្ឋ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ។<br>លោកបានស្វាគមន៍គំរោង**មរកត** ហើយរំពឹងថា នឹងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាជន ។ ប៉ុន្តែលោកព្រួយបារម្ភថាតើគំរោងនេះដើរតាមគំរោងមេឬក៏អត់ ព្រោះគំរោងខ្លះគ្រាន់តែមានប្លង់គំរោងល្អ និងមានផែនការការពារតែនៅលើក្រដាសតែប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងការអនុវត្តមិនបានតាមនោះទេ ។<br>នៅចុងបញ្ចប់នៃការពិភាក្សា លោកមានសេចក្តីរីករាយណាស់នៅក្នុងការអភិវឌ្ឍគំរោងនេះ ដោយផ្តល់ការងារឱ្យធ្វើច្រើន និងមានការរីកចំរើនដល់សេដ្ឋកិច្ចជាតិ ។ |

| | | | |
|---|---|---|---|
| ១០/៦/២០០៩ | លោក កែ ផា | ប្រធានមន្ទីរកសិកម្ម ខេត្តព្រះសីហនុ | មិនមានដីកសិកម្ម ឬផែនការសកម្មភាពនៅក្នុងតំបន់គំរោងនោះទេ ប៉ុន្តែលោកមានការព្រួយបារម្ភថា គំរោងអាចមានហេតុប៉ះពាល់ទៅលើប្រភពទឹក ឬក៏ធនធានធម្មជាតិនៅក្នុងដំណាក់ការសាងសង់គំរោង ។ ដូចនេះ ត្រូវសិក្សាឱ្យបានស៊ីជំរៅអំពីហេតុប៉ះពាល់បរិស្ថានក៏ដូចជាបំរែបំរួលអាកាសធាតុ ។<br>លោករំពឹងថាគំរោងនេះ នឹងផ្តល់ផលប្រយោជន៍ច្រើនទៅដល់សហគមន៍ ដោយបង្កើនប្រាក់ចំណូលរបស់ពួកគេ ។ លោកបានឱ្យយោបល់ទៅដល់ម្ចាស់គំរោងគួរតែបង្កើតក្រុមបោសសំអាត និងមានប្រព័ន្ធប្រព្រឹត្តកម្មសំអាតកាកសំណល់រាវមុននឹងបញ្ចេញចោលទៅក្នុងសមុទ្រ ។<br>លោកបានសំណូមពរទៅក្រុមហ៊ុនអនុវត្តគំរោងត្រូវ ដាំដើមឈើឡើងវិញ និងអភិរក្សសត្វព្រៃដែល មានស្រាប់នៅលើកោះ និងត្រូវគ្រប់គ្រងកាកសំណល់រឹង និងរាវឱ្យបានល្អបំផុត ។ |
| ១០/៦/២០០៩ | លោក ផុក ស៊ីផា | ប្រធានមន្ទីរផែនការ ខេត្តព្រះសីហនុ | ជាមួយនឹងប្លង់រចនាគំរោង និងការអនុវត្តគំរោងនៅក្នុងតំបន់កោះពស់នៃក្រុងព្រះសីហនុ លោកប្រធានបានគាំទ្រទាំងស្រុង ។ ក៏ប៉ុន្តែ លោកបានមានប្រសាសន៍ថា នៅក្នុងដំណាក់ការសាងសង់ គំរោងនេះអាចនឹងធ្វើឱ្យប៉ះពាល់ទៅដល់ការបំពុលខ្យល់ ទឹក និងចំរោះដី ។ ជាងនេះទៅទៀត ចរន្តទឹក អាចប៉ះពាល់ទៅដល់ជីវចំរុះសមុទ្រ ប៉ុន្តែលោកបានជឿជាក់ថា គំរោងនេះនឹងបានសិក្សាស៊ីជំរៅទៅលើហេតុប៉ះពាល់ និងផ្តល់វិធានការកាត់បន្ថយដ៏សមហេតុផលទៅដល់គំរោងនេះ ។<br>លោកបានស្នើសុំទៅដល់ក្រុមហ៊ុនអនុវត្តគំរោងដូចខាងក្រោម:<br>• អនុវត្តទៅតាមផែនការមេរបស់គំរោង និងផែនការមេរបស់សាលាក្រុង ។<br>• បង្កើតគណៈកម្មការតាមដានគំរោង<br>• តាមដានជាប្រចាំអំពីធនធានបរិស្ថានក្នុងអំឡុងពេលអនុវត្តគំរោង ។ |
| ១០/៦/២០០៩ | លោក សុខ សារឿន | អនុប្រធានមន្ទីរ សាធារណការ | លោកបានមានប្រសាសន៍ថាការអភិវឌ្ឍគំរោងតែងតែមានផលប៉ះពាល់កើតឡើងជាវិជ្ជមាន ឬអវិជ្ជមាន ។ ហេតុប៉ះពាល់អវិជ្ជមាន ដូចជា កាកសំណល់ ផ្សែង និងរំញ័រ ហើយលោកបានសំណូមពរទៅដល់ក្រុមហ៊ុនដូចខាងក្រោម: |

| | | | |
|---|---|---|---|
| | | និងដឹកជញ្ជូន<br>ខេត្តព្រះសីហនុ | • ត្រូវថែរក្សាដើមឈើដែលមានស្រាប់ឱ្យនៅច្រើន និងដាំឡើងវិញនៅក្នុងទីកន្លែងមួយចំនួនក្បែរតំបន់គំរោង ។<br>• ដឹកជញ្ជូនកាកសំណល់រឹងនៅពេលយប់ មិនត្រូវរំខានដល់អ្នកដែលរស់នៅក្បែរៗ នោះទេ ។<br>• ផ្តល់ប្រព័ន្ធរំដោះទឹកឱ្យបានគ្រប់គ្រាន់ ។<br>ជាចុងក្រោយលោកបានបន្ថែមថា ចង់ឱ្យមានការអភិវឌ្ឍប្រទេសកម្ពុជាឱ្យដូចជាប្រទេសជឿនលឿននានា ប៉ុន្តែមិនមែនមានន័យថាអ្វីៗទាំងអស់ដែលគេអាចបានធ្វើនៅក្នុងប្រទេសទាំងនោះ ត្រូវតែតាមគេនោះទេ គឺយើងចង់ជ្រើសរើសរបៀបនៃការអភិវឌ្ឍដោយផ្អែកទៅលើស្ថានភាពពិត និងធនធានធម្មជាតិរបស់យើងដែលមាន ។ |
| ១០/៦/២០០៩ | លោក ជិន សារិន | អភិបាលក្រុង.<br>ក្រុងព្រះសីហនុ | លោកបានដឹងខ្លះៗដែរ អំពីគំរោងអភិវឌ្ឍន៍កោះពស់នេះ និងសង្ឃឹមថាក្រុមហ៊ុនវិនិយោគគំរោងនឹងគោរពទៅតាមការអភិវឌ្ឍដោយមាននិរន្តរភាព និងបានផ្តល់ផលប្រយោជន៍ទៅដល់ប្រជាជន ជាពិសេសប្រជាជនដែលរស់នៅជិតតំបន់គំរោង និងផ្អែកទៅលើធនធានសមុទ្រ ។ ជាងនេះទៅទៀត ប្រជាជនក្រីក្រមួយចំនួនតែងតែរកទទួលទាន ដោយលក់ដូរបន្តិចបន្តួចនៅលើតំបន់ឆ្នេរនេះ ប៉ុន្តែនៅពេលដែលគំរោងបញ្ចប់ការសាងសង់ ម្ចាស់គំរោងនឹងហាមឃាត់ប្រជាជនមូលដ្ឋានមិនឱ្យទៅលេង ឬក៏លក់ដូរផលិតផលរបស់ពួកគេនៅក្នុងតំបន់ទាំងនេះទេ ឧទាហរណ៍ ដូចជា ឆ្នេរសុខាជាដើម ។ល ។<br>លោកបានសំណូមពរទៅដល់ក្រុមហ៊ុន នូវចំនុចមួយចំនួនដូចខាងក្រោមៈ<br>• គួរតែពង្រីកតំបន់ឆ្នេរសំរាប់តំបន់សាធារណៈផង<br>• ផ្តល់ការងារ ឱ្យប្រជាជនមូលដ្ឋាន<br>• រៀបចំប្រព័ន្ធលូរំដោះទឹកឱ្យបានសមស្របនៅក្នុងតំបន់គំរោង និង<br>• រៀបចំបណ្តុះបណ្តាលវគ្គខ្លីៗទៅដល់ ប្រជាជនមូលដ្ឋានអំពីទទួលបដិសណ្ឋារកិច្ច ទេសចរណ៍ និងសណ្ឋាគារ ។ |
| ១០/៦/២០០៩ | លោក ហេង សោភ័ណរិទ្ធ | អនុប្រធាន.<br>មន្ទីរធនធានទឹក | ជាការពិតណាស់ខេត្តព្រះសីហនុមានសក្តានុពលខ្ពស់សំរាប់ការអភិវឌ្ឍវិស័យទេសចរណ៍ ដោយសារតែធនធានធម្មជាតិ ។ លោកសប្បាយចិត្ត ជាមួយនឹងគំរោង**មរកត**នេះណាស់ និងវាអាចជាវិភាគទានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ |

| | | | |
|---|---|---|---|
| | | និងឧតុនិយម ខេត្តព្រះសីហនុ | ប្រជាជន និងរៀបចំក្រុងឱ្យបានល្អ។ សព្វថ្ងៃនេះ មន្ទីរធនធានទឹក និងឧតុនិយម នៅខ្វះខាតឧបករណ៍ច្រើនណាស់ទាក់ទងទៅនឹងការវាស់វែង អាកាសធាតុ ខ្យល់ សំណើម និងពន្លឺថ្ងៃ។ មានតែស្ថានីយ៍តែ១ប៉ុណ្ណោះ ដែលអាចវាស់វែងបានតែៈ កំពស់ទឹកភ្លៀង ល្បឿនខ្យល់ សំណើម និងសីតុណ្ហភាព នៅក្នុងខេត្ត។ មាន អង្គការមួយចំនួនបានជួយលើ ផ្នែកនេះដូចជាៈ JICA, DANIDA បានជួយឧបត្ថមទាំងបច្ចេកទេស និងឧបករណ៍ រួមមាន សម្ភារៈការិយាល័យ ឧបករណ៍វាស់ និងបានជួយផ្នែកជលសាស្ត្រតំបន់ក្បាលឆាយ និងជួយបណ្តុះបណ្តាលវាស់ល្បឿនទឹក កំលាំងទឹក។<br>ជាចុងក្រោយលោកបានសំណូមពរទៅដល់ម្ចាស់គំរោងឱ្យធ្វើការស្រាវជ្រាវឱ្យបានច្រើនអំពីការ ផ្លាស់ប្តូរអាកាសធាតុផ្សារភ្ជាប់ទៅនឹងពិភពលោក ហើយក្រុមហ៊ុនគួរតែបង្កើតស្ថានីយ៍ឧតុនិយមនៅក្នុងតំបន់គំរោងបើសិនជាមានលទ្ធភាព។ |
| ៣០/៣/២០១០ | លោក ស៊ឹម ស៊ីថា | ប្រធានរដ្ឋាករទឹក ខេត្តព្រះសីហនុ | រដ្ឋាករទឹកនៅក្នុងក្រុងព្រះសីហនុ គឺជាអង្គភាពស្វយ័ត្តមួយដែលបានផ្គត់ផ្គង់ទឹកស្អាតនៅទូទាំងក្រុងព្រះសីហនុ។ បច្ចុប្បន្ននេះ ប្រព័ន្ធទឹកស្អាតបានគ្របដណ្តប់ ៤០% នៃអ្នកក្រុងទាំងអស់ ជាមួយការតភ្ជាប់បណ្តាញចំនួន ៣៨៥០។ សមត្ថភាពរោងចក្រសំអាតទឹកគឺ ៨០០០ម៣/ថ្ងៃ និងមានប្រភពទឹកមកពី បឹងព្រៃកទប់ និងក្បាលឆាយ។ ការផ្គត់ផ្គង់ទឹកមានដំណើរការ២៤ម៉ោង លើ២៤ម៉ោង។ តំលៃនៃការប្រើប្រាស់ទឹកមាន៣ប្រភេទគឺៈ<br>• ពី ០-៧ម៣ ថ្ងៃ ១៥០០រៀល/ម៣<br>• ពី៨-១៥ម៣ ថ្ងៃ ១៨០០រៀល/ម៣<br>• > ១៥ម៣ ថ្ងៃ ២០០០រៀល/ម៣<br>រដ្ឋាករទឹកក្រុងព្រះសីហនុ បានធ្វើការកែលំអប្រព័ន្ធអាងប្រព្រឹត្តិកម្ម និងប្រព័ន្ធចែកចាយទឹកសំរាប់រយៈពេលវែង ដើម្បីឱ្យស្របតាមតំរូវការនៃអ្នកប្រើប្រាស់ ជាឧទាហរណ៍សេវាកម្មនេះនឹងគ្របដណ្តប់ដល់ទៅ ៨០% នៃចំនួនគ្រួសារសរុបទាំងអស់នៅក្នុងក្រុង ក្នុងឆ្នាំ២០១៥ និងអាចគ្របដណ្តប់រហូតដល់ទៅ ៨៥% នៅក្នុងឆ្នាំ២០២០។<br>ទាក់ទងទៅនឹងតំរូវការទឹកសំរាប់គំរោងអភិវឌ្ឍ**ឧកេត** លោកប្រធានរដ្ឋាករបានស្នើទៅម្ចាស់គំរោងត្រូវតែផ្តល់ព័ត៌មានជាក់លាក់នូវតំរូវការទឹកសរុបសំរាប់គំរោងទាំងមូល ទៅឱ្យរដ្ឋាករទឹកក្រុងព្រះសីហនុដើម្បីមានភាពងាយស្រួលដល់អង្គភាពក្នុងការ |

| | | | |
|---|---|---|---|
| | | | បង្កើនសមត្ថភាពផែនការរយៈពេលវែង។ ជាការពិតណាស់ រដ្ឋាករទឹកក្រុងព្រះសីហនុមានសមត្ថភាពពេញលេញ ដើម្បីផ្គត់ផ្គង់ទឹកទៅឱ្យគំរោងនេះបាន ដោយយោងទៅតាមកម្មវិធីរបស់គំរោង ម្យ៉ាងវិញទៀត ម្ចាស់គំរោងត្រូវតែបំពេញបែបបទដើម្បីសុំតភ្ជាប់បណ្ដាញទឹក ឬជាវជុំ។<br>ទោះជាយ៉ាងណាក៏ដោយ តាងនាមឱ្យអង្គភាពរដ្ឋាករទឹក និងខ្លួនខ្ញុំផ្ទាល់ខ្ញុំសូមទទួលស្វាគមន៍ចំពោះគំរោង**មរកត**នេះ និងសង្ឃឹមថាគំរោងនេះនឹងបានអនុវត្តក្នុងពេលឆាប់ៗ។ |
| ៣០/៣/២០១០ | លោក ជា សូបូឌី | ប្រធានអគ្គិសនីក្រុងព្រះសីហនុ (សាខា EDC) | បច្ចុប្បន្ននេះ សមត្ថភាពផលិតអគ្គិសនីសរុបដើម្បីផ្គត់ផ្គង់ គឺមានចំនួន១៥មេហ្គាវ៉ាត់ ក្នុងនោះ១០មេហ្គាវ៉ាត់ ត្រូវបានផ្ដល់ដោយអ្នកផលិតថាមពលឯករាជ្យ (IPP) និង៥មេហ្គាវ៉ាត់ ផលិតដោយអគ្គិសនីកម្ពុជា (EDC)។ ការប្រើប្រាស់ជាក់ស្ដែង នៅក្នុងក្រុងមានត្រឹមតែ១០មេហ្គាវ៉ាត់ទេ។<br>លោកប្រធានបានមានប្រសាសន៍ថា ប្រព័ន្ធអគ្គិសនីនៅទីនេះបានគ្របដណ្ដប់ ១០០ភាគរយនៃខ័ណ្ឌមិត្តភាព (ឥឡូវជាក្រុងព្រះសីហនុ) នាបច្ចុប្បន្ននេះ និងមានផែនការដើម្បីពង្រីកទៅដល់ស្រុកព្រៃនប់ និងស្រុកស្ទឹងហាវ ដោយមានតំរូវការប៉ាន់ប្រមាណសរុប ២មេហ្គាវ៉ាត់ (គំរោងធនាគារពិភពលោក)។ ចំពោះអត្រាតំលៃត្រូវបានរៀបចំដោយអគ្គិសនីកម្ពុជា ដូចជាតំលៃសំរាប់លំនៅដ្ឋានធម្មតា គឺ៧២០រៀល/គីឡូវ៉ាត់ម៉ោង ឬ០.១៨ដុល្លា/គីឡូវ៉ាត់ម៉ោង អគាររដ្ឋគឺ ០.២០ដុល្លា/គីឡូវ៉ាត់ម៉ោង និងអត្រាលក់ដុំ គឺផ្អែកទៅតាមការតំរូវការ (តិច មធ្យម ច្រើន)។<br>ជាងនេះទៅទៀត នៅចុងឆ្នាំ២០១២ ខេត្តព្រះសីហនុនឹងទទួលបានខ្សែបណ្ដាញនាំអគ្គិសនីពីខេត្តកំពត និងពីប្រទេសវៀតណាមកំលាំង ២៣០គីឡូវ៉ុល។ ដូច្នេះអគ្គិសនី កម្ពុជាសាខាក្រុងព្រះសីហនុ នឹងមានភ្លើងអគ្គិសនីគ្រប់គ្រាន់ដើម្បីបំរើតំរូវការថាមពលនៅក្នុងឆ្នាំខាងមុខនេះ។ ទាំងអស់នេះ មានន័យថាយើងអាចផ្ដល់សេវាកម្មភ្លើងអគ្គិសនីទៅដល់គ្រប់អ្នកប្រើប្រាស់ទាំងអស់ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗនៅក្នុងក្រុងព្រះសីហនុ រួមទាំងគំរោង**មរកត**នេះផងដែរ។<br>លោកប្រធានបានបញ្ជាក់ឡើងវិញចំពោះម្ចាស់គំរោង**មរកត**ថា អគ្គិសនីកម្ពុជាសាខាក្រុងព្រះសីហនុអាចផ្ដល់ថាមពលអគ្គិសនីទៅដល់គំរោងតាមតំរូវការបាន ប៉ុន្តែម្ចាស់គំរោងត្រូវតែផ្ដល់ចំនួនតំរូវការថាមពលជាក់លាក់ និងត្រូវបំពេញបែបបទសំរាប់ជាវជុំ |

| | | | |
|---|---|---|---|
| | | | ឬបំពេញបែបបទសំរាប់តភ្ជាប់បណ្តាញ ។<br>លោកចង់បានការអភិវឌ្ឍគំរោងជាច្រើន ដូចជាគំរោង**មរកត**នេះ ហើយលោកបានគាំទ្រគំរោងឱ្យមានការអនុវត្តដូចផែនការដែលបានគ្រោងទុក ។ |
| ៣០/៣/២០១០ | លោក ប្រាក់ ប្រាកដ | អនុប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល ខេត្តព្រះសីហនុ | លោកបានសំដែងទឹកចិត្តផ្ទាល់ខ្លួនថា ខ្ញុំតែងតែស្វាគមន៍ដល់ក្រុមសិក្សាអភិវឌ្ឍន៍ទាំងអស់ និងបានផ្តល់ឱ្យនូវទិន្នន័យមួយចំនួនលើផ្នែកឧស្សាហកម្មនៅក្នុងខេត្តព្រះសហនុនេះ ។ ជាក់ស្តែងក្រុមសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងសំរាប់សាងសង់ស្ពានកោះពស់ បានជួបជាមួយនឹងមន្ទីរតាំងពីខែមេសា ឆ្នាំ២០០៨ នៅពេលដែលចាប់ផ្តើមសាងសង់ស្ពាន ។<br>លោកអនុប្រធានមន្ទីរបានគាំទ្រគំរោងនេះ១០០% ប៉ុន្តែលោកបានស្នើទៅម្ចាស់គំរោងឱ្យសហការល្អជាមួយនឹងនាយកដ្ឋានជំនាញនានា ដើម្បីជៀសវាងឧបសគ្គផ្សេងៗដែលអាចកើតមានឡើងនៅក្នុងការសាងសង់ និងក្នុងដំណាក់កាលប្រតិបត្តិការគំរោង ។<br>ជាចុងក្រោយ លោកបានផ្តល់ឱ្យទិន្នន័យថ្មីៗ ស្តីអំពីសកម្មភាពឧស្សាហកម្ម នៅក្នុងខេត្តព្រះសីហនុទៅដល់ក្រុមសិក្សា ។ |
| ៣១/៣/២០១០ | លោក ដួង សំអាត | ប្រធានខ័ណ្ឌរដ្ឋបាលជលផល. ខេត្តព្រះសីហនុ | សកម្មភាពនេសាទនៅក្នុងខេត្តព្រះសីហនុត្រូវបានគេនេសាទគ្រប់ទីកន្លែងនៅក្នុងសមុទ្រនៃប្រទេសកម្ពុជា ដោយយោងទៅតាមរដូវកាល ។ មានទីតាំងពាក់ន្លែងដែលទូកនេសាទចូលចតនោះ ត្រូវបានគេកំណត់ដូចជា: (១) ទំនប់រលក (២) អូរត្រេះ និងទី (៣) ពាយកំពេញ ។<br>ផលិតកម្មនេសាទប្រចាំឆ្នាំ២០០៩ គឺមានចំនួន ២៨.០០០តោន រួមទាំងការចាប់ត្រីនៅតាមវាលស្រែ ។ ចំនួនអ្នកនេសាទសរុបនៅក្នុងដែន សមុទ្រអាចត្រូវបានគេបែងចែកជា២ក្រុម:<br>• ក្រុមទូកនេសាទអាជីវកម្មមានចំនួន ១៩៤០ទូក ។<br>• ក្រុមទូកនេសាទជាលក្ខណៈគ្រួសារមានចំនួន ៦០០ទូក ។<br>មានតំបន់អភិរក្សចំនួនពាក់ន្លែងត្រូវបានគេកំណត់: (១) តំបន់កោះរ៉ុង និងកោះរ៉ុងសន្លឹម (២) ស្ទឹងហាវ និង(៣) នៅតំបន់ព្រៃនប់ ។ នៅតំបន់កោះរ៉ុង និងកោះរ៉ុងសន្លឹមមានផ្កាថ្ម ស្មៅសមុទ្រ សេះសមុទ្រដែលបានរស់នៅទីនោះ និងមានប្រភេទត្រីសំខាន់ |

| | | | |
|---|---|---|---|
| | | | មួយចំនួនត្រូវដែលមានចែងក្នុងអនុក្រិត្យ លេខ១២៣ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩។ ក្រៅពីតំបន់ដែលមានរៀបរាប់ខាងលើ មានតំបន់អភិរក្សផ្សេងទៀត គឺស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ។<br>ឆ្លើយតបទៅនឹងសំនួរថា តើសកម្មភាពនេសាទនៅក្នុងតំបន់កោះពស់យ៉ាងដូចម្ដេចទៅ? លោកបានមានប្រសាសន៍ថា គ្មានការនេសាទជាលក្ខណៈអាជីវកម្ម ឬក៏ពាណិជ្ជកម្មនៅក្នុងតំបន់កោះពស់នេះទេ។ ជាទូទៅ សកម្មភាពនេសាទនៅតំបន់កោះពស់នេះជាលក្ខណៈគ្រួសារ និងនេសាទដើម្បីទេសចរណ៍កំសាន្ត ព្រោះមានផ្ទាំងថ្មធំៗជាច្រើន ដូច្នេះមានតែសន្ទូចផ្លែ១ និងសន្ទូចខ្សែជាឧបករណ៍នេសាទត្រូវបានគេប្រើជាទូទៅនៅតំបន់នេះ ។<br>លោកបានទទួលស្វាគមន៍ចំពោះគំរោង**មរកត** និងចង់ឱ្យម្ចាស់គំរោងមានសហប្រតិបត្តិការល្អជាមួយមន្ទីរជំនាញដើម្បីការពារធនធានជលផលនៅក្នុងតំបន់នេះ ។<br>ជាចុងក្រោយលោកបានសំណូមពរដល់ក្រុមហ៊ុនអនុវត្តន៍គំរោងនូវចំណុចមួយចំនួនដូចខាងក្រោម:<br>• គ្រប់គ្រងកាកសំណល់គ្រប់ប្រភេទទាំងអស់ឱ្យបានត្រឹមត្រូវ ។<br>• ការពារចំរោះដី និងការហូរធ្លាក់ចូលទៅក្នុងទឹកសមុទ្រដែលនាំឱ្យបំផ្លាញទៅដល់ផ្កាថ្ម ធនធានត្រី នៅក្នុងដំណាក់ការសាងសង់.។<br>• សហការណ៍ជាមួយនឹងរដ្ឋបាលជលផល នៅក្នុងខេត្តព្រះសីហនុដើម្បីការពារធនធានជលផលជុំវិញតំបន់កោះពស់ ។ |
| ៣១/៣/២០១០ | លោក ហ៊ុន សារុំធ | ជំទប់ទី១, សង្កាត់៣ | លោកបានផ្ដល់ឱ្យទិន្នន័យប្រជាជននៅក្នុងសង្កាត់បី ទៅដល់ក្រុមសិក្សាស្រាវជ្រាវ ។ មុខរបរចំបងរបស់ប្រជាជននៅតំបន់នេះគឺ ៦០-៧០% ជាបុគ្គលិករដ្ឋ ១៥-២០% គឺជាអ្នកនេសាទ និងពី១០-២០% ជាអ្នកលក់ដូរផ្ទាល់ខ្លួន។ បច្ចុប្បន្ននេះ មានគ្រួសារមួយចំនួនបាននេសាទត្រីនៅពេលយប់នៅជុំវិញតំបន់កោះពស់ មានចំងាយពី៥០០ ទៅ១០០០ម៉ែត្រពីច្រាំងសមុទ្រ។ អត្រាតំលៃកំលាំងពលកម្មនៅក្នុងតំបន់ គឺមានពី១០០០០-១៥០០០រៀល/ថ្ងៃ (ឬក៏២,៥-៣,៧៥ដុល្លា/ថ្ងៃ) នេះសំរាប់អ្នក ដែលគ្មានជំនាញ ប៉ុន្តែចំពោះអ្នកដែលមានជំនាញវិញបានកំរៃ ពី២០០០០-២៥០០០ រៀល/ថ្ងៃ (ឬក៏៥-៦,២៥ដុល្លា/ថ្ងៃ) ។<br>តាងនាមឱ្យប្រធានក្រុមប្រឹក្សាសង្កាត់បី លោកបានគាំទ្រនូវគំរោង**មរកត**ដែលនឹងធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍប្រទេស ។ |

| | | | |
|---|---|---|---|
| | | | លោកបានសន្យានឹងជួយសហការក្នុងកិច្ចការអនុវត្តគំរោងឱ្យបានរលូន ។<br>គំរោងនេះនឹងផ្តល់ការងារទៅដល់ប្រជាជនរបស់យើងនៅក្នុងសង្កាត់បី ដើម្បីបានចូលបំរើការងារជាកម្មករ ឬសន្តិសុខ និងអាចរកប្រាក់ពីការលក់ផលិតផលរបស់ពួកគេផ្ទាល់ ។ ហេតុដូចនេះ ខ្ញុំសូមសំណូមពរទៅដល់ម្ចាស់គំរោងឱ្យជ្រើសរើសកំលាំងពលកម្មដោយផ្តល់អាទិភាពដល់ប្រជាជនមូលដ្ឋានដើម្បីចូលធ្វើការនៅក្នុងគំរោងនេះ ។ ទោះជាយ៉ាងណាក៏ដោយ លោកបានស្នើទៅដល់ម្ចាស់គំរោងត្រូវគ្រប់គ្រងកាកសំណល់ពីសកម្មភាពរបស់គំរោង ជាពិសេសប្រេង និងខ្លាញ់ដែលលេចធ្លាយចូលទៅក្នុងសមុទ្រ ។ |
| ៣១/៣/២០១០ | លោក ម៉ា ស៊ុនហួត | អគ្គនាយករងកំពង់ផែស្វយ័តក្រុងព្រះសីហនុ | ជាការពិតមែនហើយ ខ្ញុំបានពាក់ព័ន្ធចំពោះការប្រជុំ និងពិភាក្សាជាច្រើនលើកជាមួយនឹងស្ថាប័នដែលពាក់ព័ន្ធ រួមទាំងម្ចាស់គំរោង និងក្រុមសិក្សាស្រាវជ្រាវសំរាប់ការអភិវឌ្ឍគំរោងកោះពស់ ឬគំរោង**មរកត**នេះ ។ យើងចង់ឱ្យមានការអភិវឌ្ឍដោយបច្ចេកវិទ្យាទំនើប ប៉ុន្តែការអនុវត្តគំរោងត្រូវតែគោរពតាមគោលការណ៍ណែនាំ និងច្បាប់របស់ប្រទេសកម្ពុជា ដែលអាចធានាក្នុងការអភិវឌ្ឍដោយមាននិរន្តរភាព និងការគ្រប់គ្រងបរិស្ថានបានល្អ ។<br>ពាក់ព័ន្ធនៅក្នុងកិច្ចការពារបរិស្ថាន លោកបានស្នើទៅម្ចាស់គំរោង**មរកត**ឱ្យអនុវត្តដូចខាងក្រោម:<br>• កុំធ្វើឱ្យមានការបំពុលដល់បរិស្ថាន<br>• ការពារការហូរច្រោះដី និងថ្មហូរចូលទៅក្នុងទឹក និងឃ្លងធម្មជាតិដែលមានសារៈសំខាន់សំរាប់នាវាចេញចូលកំពង់ផែ ។<br>• ការពារព្រៃឈើឱ្យបានច្រើន ដើម្បីឱ្យមានតុល្យភាពនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ ។<br>• រាល់សកម្មភាពសាងសង់ និងការបង្ហូរចេញកាកសំណល់ត្រូវតែអនុវត្តទៅតាមបទដ្ឋានបរិស្ថាន ។<br>• គ្មានការប្តឹងគ្នាទៅវិញទៅមកអំពីការបំពុលនៅក្នុងតំបន់ ជាពិសេសកាកសំណល់ ហើយសហការគ្នាដើម្បីដោះស្រាយនូវរាល់បញ្ហាបរិស្ថានដែលអាចកើតមានឡើងនៅក្នុងតំបន់នេះ ។ |
| ៣១/៣/២០១០ | លោក ងួន រស្មី | អនុប្រធានក្រុមហ៊ុនស៊ីនទ្រី សាខាក្រុង | លោកបានមានប្រសាសន៍ថា ក្នុងពេលបច្ចុប្បន្ននេះសេវាកម្មប្រមូលកាកសំណល់/សំរាមបានគ្របដណ្តប់ពី ៨៥-៩០% នៃចំនួនគ្រួសារសរុបដែលនៅក្នុងក្រុងព្រះសីហនុទាំងមូល ។ មានទីតាំងចាក់សំរាម២កន្លែង ១កន្លែងនៅក្នុងឃុំបិតត្រាង ស្រុកព្រៃនប់ |

| | | | |
|---|---|---|---|
| | | ព្រះសីហនុ | (កំពុងដំណើរការ) និង១កន្លែងមានចំងាយ២៥គ.ម ពីទីតាំងបិតត្រាង ឆ្ពោះទៅទីរួមស្រុកព្រៃនប់ (នៅក្នុងផែនការឆ្នាំ២០១៥)។<br>សំរាមតាមផ្ទះ និងសំណល់ឧស្សាហកម្មត្រូវបានប្រមូល ដឹកជញ្ជូន និងបោះចោលនៅកន្លែងចាក់សំរាម។ ការប្រមូលថ្លៃប្រមូលសំរាម គឺត្រូវបានប្រមូលដាច់ដោយឡែកពីវិក័យបត្រទឹក និងអគ្គិសនី ហើយតំលៃសេវាកម្មប្រមូលសំរាមទីនេះ គឺមានចន្លោះពី ៣៩០០រៀល ឬ០.៧៨ដុល្លា/ខែ ទៅ ៥៨៥០រៀល/ខែ ឬ១.៤៦ដុល្លា/ខែសំរាប់លំនៅដ្ឋានធម្មតា ប៉ុន្តែសំរាប់ភូមិគ្រឹះ គឺតំលៃ ១១៧០០រៀល ឬ២.៩៣ដុល្លា/ខែ ហើយតូបលក់ដូរតូចតាចយកតំលៃពី៣-៣០ដុល្លា/ខែ ជំនួញខ្នាតមធ្យមយកពី៣០-៧០ដុល្លា/ខែ និងជំនួញខ្នាតធំ និងផ្សារ តំលៃពី៧០-២៥០ដុល្លា/ខែ។ ចំពោះប្រភេទ រោងចក្រយកតំលៃ ២០០ដុល្លា/ខែ និងកំពង់ផែអន្តរជាតិយកតំលៃ ១៥០០ដុល្លា/ខែ។<br>យោងលើសមត្ថភាពសេវាកម្មក្រុមហ៊ុនស៊ីនទ្រីសាខាក្រុងព្រះសីហនុ យើងអាចផ្តល់សេវាកម្មដល់គំរោង**មរកត**នេះបាន។ ទោះជាយ៉ាងណាក៏ដោយ លោកបានស្នើសុំទៅម្ចាស់គំរោងត្រូវរៀបចំទីតាំងដាក់សំរាមឱ្យបានសមរម្យ ដោយបែងចែកប្រភេទសំណល់ដែលអាចប្រើប្រាស់ឡើងវិញបាន។ |
| ០១/៤/២០១០ | លោក ឌី សូភី | អនុប្រធានខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ | នៅក្នុងក្រុងព្រះសីហនុ មានតំបន់ការពារព្រៃឈើតែ១កន្លែងគត់ដែលគេហៅថាតំបន់ ក្បាលឆាយ។ ជារៀងរាល់ឆ្នាំខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុមានកម្មវិធីដាំដើមឈើឡើងវិញ និងបានផ្តល់គ្រាប់ពូជឈើទៅឱ្យប្រជាជនសំរាប់ដាំដុះ។<br>ឆ្លើយតបទៅនឹងសំណួរអំពីប្រភេទសត្វព្រៃនៅលើកោះពស់ លោកបានឆ្លើយថា មិនទាន់មានការសិក្សាស្រាវជ្រាវទេទៅលើប្រភេទសត្វព្រៃនៅទីនេះទេ។<br>តាងនាមឱ្យខ័ណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះសីហនុ និងខ្លួនលោកផ្ទាល់សូមគាំទ្រទូវការអនុវត្តគំរោង**មរកត**នេះ គ្រាន់តែស្នើទៅដល់ម្ចាស់គំរោងឱ្យសហប្រតិបត្តិការជាមួយនឹងការិយាល័យរបស់យើងខ្ញុំ ដូចជាការផ្តល់ឯកសារស្តីអំពីការអនុវត្តគំរោង ជាពិសេស លិខិតអនុញ្ញាតឱ្យសាងសង់ និងកម្មវិធីសាងសង់ នៅលើកោះពស់ជាព័ត៌មាន ដើម្បីជួយសំរបសំរួលកាប់ព្រៃឈើ សំរាប់ការដ្ឋានសាងសង់នៅទីនោះ។ |

Draft

## ៥.៥ ការសន្និដ្ឋាន និងអនុសាសន៍

តាមលទ្ធផលនៃកិច្ចពិគ្រោះយោបល់ជាសាធារណៈ និងកិច្ចប្រជុំជាមួយអ្នកដែលពាក់ព័ន្ធ គេអាចសន្និដ្ឋានថា ប្រជាជនមូលដ្ឋាន មន្ទីរជំនាញនៅក្នុងក្រុងព្រះសីហនុ វិស័យឯកជន អាជ្ញាធរកំពង់ផែ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់បានទទួលស្វាគមន៍គាំទ្រគំរោងមរកត ។ ពួកគេទាំងអស់បានយល់ពីគំរោងមរកត នឹងផ្តល់ផលប្រយោជន៍ច្រើនទៅដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងខេត្តទាំងមូល និងផ្តល់ឱកាសការងារច្រើនទៅដល់ប្រជាជនមូលដ្ឋាន និងមានការរីកចំរើនសេដ្ឋកិច្ចជាតិ ។

ទោះជាយ៉ាងណាក៏ដោយ គំរោងនឹងអាចផ្តល់នូវបញ្ហាខ្លះៗទៅដល់កំពង់ផែកំពង់សោម ការរំខាន ដល់នាវាខ្នាតធំ និងអាចមានខ្យល់បោកបក់មកលើតំបន់កំពង់ផែ ហើយអាចកាត់បន្ថយប្រសិទ្ធភាពសេវាកម្មរបស់កំពង់ផែ ។ ក្រៅពីនេះ សកម្មភាពសាងសង់របស់គំរោងអាចមានផលប៉ះពាល់ទៅដល់ប្រព័ន្ធអេកូឡូស៊ីឆ្នេរ និងសកម្មភាពទេសចរណ៍ដែលស្ថិតនៅក្បែរតំបន់គំរោង ។

អនុសាសន៍ ឬក៏យោបល់មួយចំនួនដែលត្រូវបានគេលើកឡើងពីការពិគ្រោះយោបល់ និងកិច្ចប្រជុំជាមួយនឹងប្រជាជន និងអ្នកដែលពាក់ព័ន្ធនឹងគំរោងមានដូចតទៅ:

- លើកទឹកចិត្ត/ជំរុញការអនុវត្ត ដោយហេតុថាតំរូវការអភិវឌ្ឍន៍ និងធ្វើឱ្យប្រជាជនមានទំនុកចិត្តទៅលើគំរោងនេះ ។
- ការសាងសង់ត្រូវតែអនុលោមទៅតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងនានា និងអង្គភាពជំនាញនៃរាជរដ្ឋាភិបាលកម្ពុជា ។
- ផ្តល់ព័ត៌មានគំរោង និងផលប្រយោជន៍របស់គំរោងទៅដល់ប្រជាជន ។
- សហប្រតិបត្តិការល្អជាមួយនឹងស្ថាប័នជំនាញនៅក្នុងការងារសាងសង់ដើម្បីឱ្យស្របទៅតាមគោលការណ៍/បទបញ្ជា និងច្បាប់របស់ប្រទេសកម្ពុជា ។
- ធានាក្នុងការគ្រប់គ្រងកាកសំណល់ (រឹង និងរាវ) ពីសកម្មភាពគំរោង ។
- ត្រូវផ្តល់ព័ត៌មានពីសកម្មភាពការងារប្រចាំសប្តាហ៍ ឬក៏ប្រចាំខែទៅដល់មន្ទីរជំនាញដែលពាក់ព័ន្ធ ។
- ត្រូវអនុញ្ញាតឱ្យអ្នកឆ្លងកាត់ស្ពានដោយមិនចាំបាច់បង់ប្រាក់ ។
- ស្ថាបនាការិយាល័យទេសចរណ៍នៅខាងមុខស្ពាន (ដូចជាស្ពានសេកុង នៅក្នុងខេត្តស្ទឹងត្រែង) ។
- ប្រសិនបើមានលទ្ធភាពក្រុមហ៊ុនអាចរៀបចំស្ថានីយ៍ប៉ូលីសទេសចរណ៍នៅចំណុចចាប់ផ្តើមនៃស្ពាន ។
- ត្រូវអនុញ្ញាតឱ្យវិស្វករពី ២នាក់ ទៅ ៣នាក់ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនចូលធ្វើការនៅក្នុងអំឡុងពេលសាងសង់ ដើម្បីបណ្តុះបណ្តាលសមត្ថភាពដល់អ្នកបច្ចេកទេសកម្ពុជា ។

Draft